# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ២៦ ខែតុលា លេខ ១០

ព.ស. ២៤៩៧ — គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

*ផ្នែកសាសនា* — បញ្ជីរឿង — *ទំព័រ*

— វីរិយារម្ភកថា . . . . . . . . . . . . . . . ព្រះគ្រូ កែ - អៀន . . . . . . . . ៧២៣
— ពុទ្ធបរិស័ទ គឺអ្នកណា (តចប់) . . . . . . . ឃុនបណ្ណានុរ័ក្ស ប៊ូ- ប៊ូ . . . . . ៧៣៥
— បញ្ញាសជាតក ភាគទី ២ (តមក) . . . . . បណ្ឌិតមហា ឈឹម- ស៊ុម . . . . ៧៥៣

*ផ្នែកអក្សរសាស្ត្រ*

— រឿងសៅរ៍សោយ (តមក) . . . . . . . . . ព្រះមហាឧត្ដមវិជ្ជា ប៊ុង- ប៉ម . . . ៧៦៧
— រឿងសាមកុក (តមក) . . . . . . . . . . . . ឧកញ៉ា នូ- កន . . . . . . . . . ៧៧៤
— នាលៈនឹងទមយន្តី (តមក) . . . . . . . . . អ្នកស្រី ស៊្រីន-សារីយ៉ាន់ . . . . ៧៨០
— ដំណឹងតាមខ្យល់ក្នុងកន្តារៈ (តមក) . . . . លោក ផេង - ជឺវ . . . . . . . . ៧៨៦
— រឿងបល្ល័ង្កទិព្យ . . . . . . . . . . . . . . . លោកភ៉ាយ - ប៊ុក . . . . . . . . . ៧៩១

*កំណត់និងប្រវត្តិការណ៍*

— ពិធីបុណ្យឆ្លងសាលាបាលីរង វត្តព្រះព្រហ្ម.
រតន៍ វិវត្រសៀមរាប . . . . . . . . . . . . . ព្រះគ្រូ កែ - អៀន . . . . . . . . ៧៩៤

មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០រ.០០

# KAMBUJASURIYA

Revue religieuse et litteraire éditée par l'Institut Bouddhique


## *TABLE DES MATIÈRES*


PARTIE RELIGIEUSE: Page

— Viriyarambhakatha . . . . . *M. Vén. KER - OEURN* . . . . 723

— Les Bouddhistes (suite et fin) . *M. BOU-PO* . . . . . . . . . 735

— Pannasajataka vol-II (suite) . *M. CHHIM-SOUM* . . . . . . 753

PARTIE LITTERAIRE:

— Le « SAU-SOY » ou l'influence saturnienne (suite) . . . . . *Vén. PEUNG-PAM* . . . . . . 767

— Histoire de Samkok (suite) . . *Oknha NOU-KAN* . . . . . . 774

— Nala et Damayanti (suite) . . *Mme SRIN-SARIS-YANN* . . . 780

— Le souffle du désert (suite) . *M. PHENG-CHRIV* . . . . . . 786

—Les trente deux récits du TRONE *M. RAY - BUC* . . . . . . . . 790

NOTES ET CHRONIQUES:

— L'inauguration de l'Ecole Elémentaire de Pali de vat Brah Promrat *Vén. KER - ŒURN* . . . . . 794



Prix d'abonnement annuel (comprenant 12 numéros) 200$00

# វិរិយារម្ភកថា

## ព្រះគ្រូបាឡាទវង្សអនុគណ កែ-អឿន (វិរិយបញ្ញោ)

វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប

រៀបរៀង

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

វេលានេះ នឹងសំដែងព្រះសទ្ធម្មទេសនាក្នុងវិរិយារម្ភកថា ដើម្បីប្រដាប់សតិបញ្ញា នឹងជាគ្រឿងជួយជ្រោមជ្រែងឲ្យកើតឧស្សាហៈក្នុងសម្មាបដិបត្តិ ដល់សាធុជនពុទ្ធបរិស័ទទួទៅតាមពុទ្ធានុសាសនីថា:

កោសជ្ជំ ភយតោ ទិស្វា វិរិយារម្ភញ្ច ខេមតោ
អារទ្ធវិរិយា ហោថ ឯសា ពុទ្ធានុសាសនី

ប្រែថា "អ្នកទាំងឡាយ បើឃើញសេចក្តីខ្ជិលថាជាភ័យហើយ ឃើញសេចក្តីព្យាយាមដ៏មុឺងម៉ាត់ថាជាសេចក្តីក្សេមហើយ ចូរជាអ្នកមានសេចក្តីព្យាយាមដ៏មុឺងម៉ាត់ចុះ, នេះជាពុទ្ធានុសាសនី" ។

អធិប្បាយថា: ធម្មតាបុគ្គលគ្រប់រូបរមែងមានករណីយកិច្ចដែលត្រូវធ្វើ ទាំងជានាទីរបស់ខ្លួននិងនាទីរបស់បុគ្គលដទៃ ៗ ឯនាទីរបស់ខ្លួននោះ គឺការតាំងខ្លួនឲ្យបានជាអ្នកមានឋានៈខ្ពង់ខ្ពស់ក្នុងលោកនេះ, ឯនាទីរបស់បុគ្គលដទៃនោះ គឺនាទីដែលខ្លួនត្រូវធ្វើដល់អ្នកដទៃតាមសមគួរដល់ឱកាស ដូចជាខ្លួននៅក្នុងឋានៈជាអ្នកតូច ក៏ត្រូវស្តាប់បង្គាប់លោកអ្នកធំ ជួយ

ធ្វើធុរៈរបស់លោកឲ្យសម្រេច ប្រព្រឹត្តខ្លួនឲ្យជាទីស្រឡាញ់គាប់ចិត្តលោកអ្នកធំៗ ក៏ត្រូវមានមេត្តាករុណាដល់អ្នកតូច ជួយអនុគ្រោះអ្នកតូចឲ្យបានសុខផង ធ្វើខ្លួនឲ្យជាទីពឹងពំនាក់របស់អ្នកតូច រហូតដល់ករណីយកិច្ចផ្សេងៗ មានកិច្ចដែលទាក់ទងដល់ជាតិ - សាសនា - មហាក្សត្រដោយឋានៈជាពលរដ្ឋរបស់ជាតិនិងរបស់សាសនាផងៗ ករណីយកិច្ចទាំងអស់នេះ បើបុគ្គលៈធ្វើបានសម្រេចដោយរៀបរយ គឺជាគុណធ្វើខ្លួន ឲ្យមានតម្លៃថ្លៃថ្នូរ ទាំងបានឈ្មោះថាខ្លួនជាទីពឹងរបស់ខ្លួន ។ ជនបែបនេះមិនគ្រាន់តែជាទីពឹងរបស់ខ្លួនប៉ុណ្ណោះទេ អាចជាទីពឹងអាស្រ័យរបស់ជនឯទៀតបាន ។ ទីពឹងទាំងពីរប្រការនេះ មនុស្សគ្រប់គ្នាមែនត្រូវការប្រាថ្នាដូចគ្នា ប៉ុន្តែមានបុគ្គលខ្លះមិនអាចសម្រេចលទ្ធផលតាមប្រាថ្នា ។ រឿងនេះមិនមែនព្រោះអ្វី ព្រោះតែសេចក្តីខ្ជិលដែលជាមេកិលេសមួយធំ នាំមិនឲ្យបានសម្រេចដូចប្រាថ្នា ។

សេចក្តីខ្ជិលនេះ ជាកិលេសមួយដែលមានទោសជាអនេកប្បការ ហើយជាកំពែងព័ទ្ធរាំងមិនឲ្យសេចក្តីចំរើនចូលមកក្នុងសន្តានបាន ធ្វើឲ្យចិត្តរួញរាក្នុងការងារគ្រប់ជំពូក ទោះបីធ្វើការងារណា ក៏ធ្វើសោះតែគេថា មិនធ្វើដោយតាំងចិត្តប៉ងប្រឹងឲ្យសម្រេច ។ មនុស្សខ្ជិលច្រើនអាងហេតុថា ពេលនេះក្តៅណាស់, រងារណាស់, ត្រជាក់ណាស់, ព្រឹកណាស់, ល្ងាចណាស់, ឃ្លានណាស់, ឆ្អែតណាស់ ដូច្នេះ ហើយមិនធ្វើការងារ ។

ការសិក្សាសូត្ររៀនសិល្បវិជ្ជា បើខ្ជិលមិនព្យាយាមសូត្រទន្ទេញទេ សិល្បវិជ្ជាការនោះ គឺដល់នូវសេចក្ដីវិនាសសាបសូន្យអស់ទៅ; បុគ្គលអ្នកគ្រប់គ្រងផ្ទះសម្បែង បើខ្ជិលមិនជួសជុលផ្ទះដែលគ្រាំគ្រាទេ ផ្ទះនោះក៏នឹងបាក់បែកខ្ទាតខ្ទាយអន្តរាយទៅ, គ្រហស្ថបព្វជិត បើខ្ជិលមិនខំស្អាតដំរេះដុសលាងកាយ ឬគ្រឿងប្រើប្រាស់ទេ ពន់កាយឬគ្រឿងប្រើប្រាស់នោះក៏នឹងមានពណ៌ទ័ក្លិនសៅហ្មងមិនស្អាត, បុគ្គលអ្នកមានទ្រព្យសម្បត្តិ បើខ្ជិលមិនប្រុងប្រយ័ត្នរក្សាឲ្យល្អទេ ទុកដូចជាបើកឱកាសឲ្យចោរលួចយកទៅបាន ។ សេចក្ដីនេះសមដូចពុទ្ធភាសិតថា:

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា

មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ

ប្រែថា: មន្តទាំងឡាយមានការមិនស្វាធ្យាយន៍ជាមន្ទិល, ផ្ទះទាំងឡាយមានការមិនជួសជុលជាមន្ទិល, សេចក្ដីខ្ជិលច្រអូសជាមន្ទិលដល់ពណ៌សម្បុរ, សេចក្ដីប្រមាទជាមន្ទិលរបស់អ្នករក្សា ។

បុគ្គលដែលខ្ជិលមិនធ្វើការងារ រមែងមិនបានទទួលនូវទ្រព្យដែលជាហេតុឲ្យកើតសេចក្ដីសុខកាយ សុខចិត្ត ។ មនុស្សខ្ជិលរមែងបានជួបប្រទះតែនូវវិនាសអន្តរាយភោគទ្រព្យ មិនដែលបានទទួលសេចក្ដីសុខដែលកើតអំពីលោកិយទ្រព្យ មិនបាច់និយាយដល់ទៅសេចក្ដីសុខ ដែលជាលោកុត្តរទ្រព្យនោះឡើយ ។

ម្យ៉ាងទៀត មនុស្សខ្ជិល ក្រៅអំពីក្លាត់បាកប្រយោជន៍ បាកសេចក្ដីសុខនោះហើយ នៅមានការប្រព្រឹត្តមិច្ឆាជីវៈ ប្រកបការងាររកស៊ីមិនត្រឹមត្រូវតាមគន្លងធម៌មានលួចប្លន់ជាដើម ដោយសំគាល់ការងារជាសម្មាអាជីវៈ ជាជាការលើបាកហួសនិស្ស័យខ្លួន; មនុស្សកំជិលនោះឈ្មោះថាធ្វើទុក្ខឲ្យមានដល់ខ្លួនឯង ក្នុងបច្ចុប្បន្ន និងអនាគត គឺក្នុងបច្ចុប្បន្នមានក្ដៅក្រហាយព្រោះត្រូវម្ចាស់គេប្រទូសរ៉ាយ ហើយនៅមានគេចាប់ចងដាក់ទោសទៀត ឬបើគេចាប់មិនបានក៏គង់មានភ័យខ្លាចនឹករអា ដេកមិនលក់ បក់មិនល្ហើយ, កាលបើលះលោកនេះទៅហើយ ទោសនោះក៏នៅជាប់តាមទៅឲ្យផលទៀត ។ សមដូចព្រះពុទ្ធដីកាដែលព្រះបរមគ្រូទ្រង់ត្រាស់ទុកក្នុងសព្វលហុសសូត្រថា: "ម្នាលភិក្ខុទាំងឡាយ! បុគ្គលប្រព្រឹត្តនូវការកាន់យកវត្ថុដែលគេមិនបានឲ្យ រមែងធ្លាប់ខ្លួនតែលួចដែលជាហេតុឲ្យធ្លាក់នរក; ការកាន់យករបស់ដែលម្ចាស់គេមិនបានឲ្យ មានទោសយ៉ាងស្រាលបំផុត ត្រឹមធ្វើមនុស្សអ្នកប្រព្រឹត្តឲ្យវិនាសបាកភោគទ្រព្យ, កិរិយារកស៊ីដូច្នេះជាអំពើរបស់មនុស្សខ្ជិល, មនុស្សខ្ជិលមិនធ្វើការងារប្រព្រឹត្តតែចោរកម្មនោះ មិនអាចនឹងគ្រប់គ្រងផ្ទះបានទេ ភោគទ្រព្យដែលមិនទាន់កើត ក៏នឹងមិនកើតឡើង ភោគទ្រព្យដែលកើតឡើងហើយនឹងវិនាសសាបសូន្យទៅវិញ ទ្រព្យទាំងឡាយចេះតែកន្លងវំលងបុគ្គលនោះទៅ" ។ បុគ្គលខ្ជិលជាមនុស្សឥតទ្រព្យឥតប្រាជ្ញា, នៅក្នុងលោកនេះក៏តាំងខ្លួនមិនបាន ជាមនុស្សអស់ទីពឹងពាក់ពំនាក់អាស្រ័យ ឈម

មុខទៅពីធីនណា ក៏ពីធីមិនបានដូចចិត្តប៉ង ក្លាយទៅជាមនុស្សក្រីក្រ លំបាក អស់សេចក្តីក្រេមក្សាន្តអំពីខ្លួន ជាមនុស្សលិចចុះក្នុងសេចក្តីទុក្ខ មិនមានថ្ងៃណាដែលនឹងបានផុសងើបមុខឡើងបានឡើយ ដូចគល់ជ្ញំថ្ម ដែលធ្លាក់ចុះក្នុងស្ទឹងដ៏ជ្រៅ ទោះបីមានជីវិតរស់នៅក៏រកសេចក្តីចំរើនមិនមាន ព្រោះហេតុនេះហើយទើបលោកពោលថា: គិរិយាខ្ជិលច្រអូសនេះជាភ័យមួយយ៉ាងធំក្រៃលែង ៗ ប្រទេសណាសម្បូណ៌ដោយប្រជាជនខ្ជិលច្រើន ប្រទេសនោះរមែងគប់ទៅលើភ័យតែម្យ៉ាងប៉ុណ្ណោះ ៗ កាលបើប្រជាជនឃើញសេចក្តីខ្ជិលថាជាភ័យហើយ គួរព្យាយាមប្រឹងប្រែងប្រកបការងាររបស់ខ្លួន ដោយមិនរួញរាត្អូញត្អែរ ទោះបីមានឧបសគ្គគ្រោះថ្នាក់យ៉ាងណាមកកកំង ក៏មិនលះបង់កិច្ចការនោះ ឧស្សាហ៍ខ្វល់ខ្វាយតស៊ូទាល់តែមានជ័យជំនះឈ្នះឧបសគ្គ ត្រាតែបានសម្រេចផលដែលខ្លួនប្រាថ្នា ៗ

សេចក្តីព្យាយាមនោះមានលក្ខណៈ ៣ ប្រការគឺ:

១.— អនិក្ខិត្តធុរតា ការមិនដាក់ធុរៈចោល

២.— អនិព្ពុត្តតា ការមិនទៀយណាយធុញទ្រាន់

៣.— អសង្គរតា ការធ្វើការងារតាមកាលវេលាមិនបណ្តោះដៃ ៗ

សេចក្តីព្យាយាមនេះ បើបុគ្គលយកទៅប្រើក្នុងផ្លូវល្អដែលហៅថា សម្មាវាយាម: (ព្យាយាមត្រូវ) នោះរមែងអំណោយផលល្អ, បើនាំយកទៅប្រើក្នុងផ្លូវមិនល្អដែលហៅថា មិច្ឆាវាយាម: (ព្យាយាមខុស) រមែង

អំណោយផលអាក្រក់ ៗ តែសេចក្ដីបំណងក្នុងភាសិតនេះ ព្រះបរមគ្រូទ្រង់សំដៅយកព្យាយាមដែលត្រូវ ព្រោះសេចក្ដីព្យាយាមត្រូវអាចឲ្យសម្រេចប្រយោជន៍ខ្លួននឹងបុគ្គលដទៃទៅ ទាំងមិនជាការបៀតបៀននូវគ្នានឹងគ្នាផង ៗ

រឿងនេះ គប្បីឃើញតួយ៉ាងដូចព្រះបរមសាស្ដា កាលទ្រង់តាំងសេចក្ដីព្យាយាមស្វែងរកពោធិញ្ញាណ ចាប់តាំងពីទ្រង់បំពេញបារមីមកអស់រយៈវេលាជាច្រើនសែនកប្បទល់គ្នានឹងបច្ឆិមជាតិ, មុនពេលដែលព្រះអង្គបានត្រាស់ដឹង ក៏បានស្ដេចទៅសិក្សាក្នុងសំណាក់នៃគ្រូដទៃ និងទ្រង់បំពេញព្យាយាមយ៉ាងតឹងរ៉ឹង រហូតដល់បានត្រាស់នូវអនុត្តរសម្មាសម្ពោធិញ្ញាណសមតាមបំណង ៗ សេចក្ដីសម្រេចនេះ ឲ្យផលយ៉ាងធំក្រៃលែង គឺព្រះអង្គទ្រង់រួចផុតចាកសេចក្ដីទុក្ខបាន ហើយថែមទាំងស្ដេចចារិកទៅប្រៀនប្រដៅវេនេយ្យសត្វ ឲ្យបានផុតចាកទុក្ខផងទៀត រហូតដល់ទ្រង់ប្រតិស្ឋានព្រះធម៌វិន័យល្អប្រពៃ ទុកជាសាសនា ឲ្យពួកយើងប្រព្រឹត្តប្រតិបត្តិតាមដរាបដល់សព្វថ្ងៃនេះ នេះជាផលនៃសេចក្ដីព្យាយាមត្រូវ ៗ សូម្បីក្នុងកាលជាខាងក្រោយអំពីកាលដែលព្រះអង្គត្រាស់ដឹងមក ព្រះអង្គបានត្រាស់នឹងភិក្ខុទាំងឡាយថា អប្បដិវានី សទាហំ បទហាមិ ជាដើម (ប្រែថា) "ម្នាលភិក្ខុទាំងឡាយ! តថាគតមិនជាអ្នកថយក្រោយ, ផ្ដើមតាំងសេចក្ដីព្យាយាមថា សាច់នឹង

ឈាមក្នុងរាងកាយរបស់តថាគតនេះ ចង់រីងស្ងួតហួតហែងទៅ សល់នៅតែស្បែកនិងឆ្អឹងក៏ដោយ, ផលឯណាដែលគប្បីសម្រេចដោយកំលាំងនៃបុរស ដោយព្យាយាមរបស់បុរស ដោយសេចក្តីនឿយហត់បែកញើសហូរញើសរបស់បុរស បើមិនទាន់បានសម្រេចផលនោះទេ តថាគតនឹងមិនបញ្ឈប់សេចក្តីព្យាយាមជាដាច់ខាត" ។

ត្រង់ដែលថា "ឃើញសេចក្តីព្យាយាមដ៏មុឹងម៉ាំថាជាសេចក្តីក្សេម" ក្នុងពុទ្ធភាសិតនេះ គឺឃើញថាសេចក្តីព្យាយាមជាហេតុនៃផលគឺសេចក្តីសម្រេចអំណោយផលល្អទាំងក្នុងគតិលោកនិងគតិធម៌ ។ ក្នុងគតិលោក, មានព្រះពុទ្ធភាសិតដែលត្រាស់ដល់អាឡវកយក្ខក្នុងយក្ខសំយុត្តជាគ្រឿងអាងថា បដិរូបការី ធុរវា ឧដ្ឋាតា វិន្ទតេ ធនំ "អ្នកមានធុរៈធ្វើការដោយម៉ត់ចត់ រមែងរកទ្រព្យបាន" ។ ក្នុងគតិធម៌, ដូចព្រះអង្គទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ! អរិយសាវកក្នុងព្រះធម៌វិន័យនេះ ជាអ្នកមានសេចក្តីព្យាយាមតឹងរឹង ដើម្បីលះអកុសលធម៌ ដើម្បីសេចក្តីដល់ព្រមនៃកុសលធម៌ ជាអ្នកមានកំលាំងកំហែង ទោះបីនឿយហត់ក៏មិនដាក់ធុរៈក្នុងកុសលធម៌ ។ លោករមែងពេញចិត្តនឹងសេចក្តីព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គងចិត្តផ្តើមតាំងចិត្តទុក ដើម្បីមិនឲ្យកើតឡើងនៃអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើតឲ្យកើតឡើង ដើម្បីតាំងនៅ ដើម្បីសេចក្តីមិនសាបសូន្យ

ដើម្បីកើតឡើងដោយក្រៃលែង ដើម្បីសេចក្ដីចំរើន ដើម្បីសេចក្ដីបរិបូណ៌នៃកុសលធម៌ ដែលកើតឡើងហើយដូច្នេះជាដើម" ។

កាលបើបុគ្គលពិចារណាឃើញសេចក្ដីខ្ជិលថាជាភ័យ ឃើញសេចក្ដីព្យាយាមដ៏មុះមុតថាជាដែនកើតនៃសេចក្ដីក្សេមក្សាន្ត គឺឃើញសេចក្ដីខ្ជិលដូចអាសិរពិស ឃើញសេចក្ដីព្យាយាម ដូចឱសថដែលបំបាត់ពិសដូច្នេះហើយ ក៏គប្បីលះបង់សេចក្ដីខ្ជិលចោលចេញ ហើយប្រកបសេចក្ដីព្យាយាមក្នុងការងារដែលត្រឹមត្រូវឡើង ដូចមានពុទ្ធភាសិតថា:

អនត្ថំ បរិវជ្ជេតិ អត្ថំ គណ្ហាតិ បណ្ឌិតោ

"បណ្ឌិតរមែងលះវៀរនូវរបស់ដែលគ្មានប្រយោជន៍ កាន់យកតែរបស់ដែលមានប្រយោជន៍" ។

ក្នុងគតិលោក. សេចក្ដីព្យាយាមជាកំលាំងយ៉ាងមាំក្នុងកិច្ចការតូចធំៗ បុគ្គលដែលនឹងតាំងខ្លួនបាន រហូតដល់មានកិត្តិយសខ្ពស់ក្ដី ប្រទេសជាតិនឹងរុងរឿងឈានទៅមុខក្ដី ក៏ព្រោះប្រជាជនជាពលរដ្ឋរបស់ប្រទេសនោះក្នុងម្នាក់ៗសុទ្ធតែជាអ្នកមានសេចក្ដីព្យាយាមខំប្រឹងប្រកបការងារតាមនាទីរបស់ខ្លួនៗ មិនវង្វេងវង្វាន់ក្នុងទៅក្នុងផ្លូវអបាយមុខ ដែលជាប្រធាននៃសេចក្ដីវិនាស គឺមិនផឹកសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ព្រោះជាហេតុឲ្យធ្វើសេចក្ដីអាក្រក់ឯទៀតៗ, មិនដើរកណ្ដាលយប់ព្រលប់ ព្រោះជាហេតុឲ្យខូចការងារនឹងកសេចក្ដីរង្កៀសសង្ស័យដល់

មនុស្សទាំងឡាយ. មិនលេងល្បែងភ្នាល់មានប្រការផ្សេងៗព្រោះជាហេតុឲ្យខូចទ្រព្យសម្បត្តិ ទីងធ្វើនិស្ស័យឲ្យជាកទាបថយចុះ, មិនគប់មនុស្សអាក្រក់ជាមិត្តព្រោះជាហេតុនាំឲ្យធ្វើសេចក្ដីអាក្រក់ មិនជាវីទំនុកទុកចិត្តជឿរបស់មនុស្សទាំងឡាយ ។ អ្នកដែលមានសេចក្ដីប្រាថ្នានូវសេចក្ដីចំរើនដោយគោគទ្រព្យ គប្បីវៀរចាកហេតុនៃសេចក្ដីវិនាសទាំងនេះចេញ ។

បើអ្នកណាសង្ឃឹមពឹងផ្អែកទៅលើអ្នកដទៃទីងបច្ច័យខាងក្រៅ មានសង្ឃឹមដោតជាគាពសីជាដើម សេចក្ដីសង្ឃឹមបែបនេះ ជារបស់មិនគាប់គួរសោះ ព្រោះជាគ្រោះបង់ច្រើនជាងគ្រោះបាន ។ ព្រោះហេតុនោះទើបគួរកំចាត់ឲ្យអស់ចេញ ហើយបែរមកនិយមត្រេកអរជឿមាំក្នុងកម្លាំងកាយទីងសតិបញ្ញារបស់ខ្លួន ទើបទីងបានសម្រេចផលសមតាមបំណងមិនខាន ។

ចំណែកគតិធម៌, បុគ្គលដែលចំរើនល្អលាស់ក្នុងធម៌ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ រហូតដល់រលាស់ខ្លួនចេញចាកទុក្ខបាន ក៏ព្រោះអាស្រ័យសេចក្ដីព្យាយាម ដូចមានពុទ្ធភាសិតថា: វីរិយេន ទុក្ខមច្ចេតិ "បុគ្គលដែលទីងកន្លងផុតសេចក្ដីទុក្ខទៅបាន ក៏ព្រោះសេចក្ដីព្យាយាម" ។

សេចក្ដីព្យាយាមនោះចែកជា ៤ គឺ:

១ – ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើងក្នុងសន្ដាន,

២ – ព្យាយាមលះបាបដែលកើតឡើងហើយ,

៣- ព្យាយាមធ្វើកុសលឲ្យចំរើនឡើងក្នុងសន្តាន,

៤- ព្យាយាមរក្សាកុសលដែលកើតឡើងហើយមិនឲ្យសាបសូន្យ ៗ

ប៉ុន្តែសេចក្ដីព្យាយាមទាំង ៤ នេះ បើបំព្រួញឲ្យខ្លីចុះមកមានត្រឹម ២ គឺព្យាយាមលះបាប ១, ព្យាយាមបំពេញកុសល ១ ទាំងពីរយ៉ាងនេះជាកិច្ចគួរធ្វើ ៗ ប៉ុន្តែមនុស្សពាលយល់ឃើញថាលំបាកធ្វើ ចំណែកបណ្ឌិតយល់ឃើញថា ងាយធ្វើ ព្រោះចិត្តរបស់បណ្ឌិតតែងត្រេកអរក្នុងការប្រព្រឹត្តល្អជានិច្ច ដូចពុទ្ធភាសិតថា សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ សេចក្ដីល្អមនុស្សល្អធ្វើបានដោយងាយ, សេចក្ដីល្អមនុស្សអាក្រក់ធ្វើបានដោយលំបាក" ៗ

មនុស្សល្អ រមែងខ្វល់ខ្វាយក្នុងការលះសេចក្ដីអាក្រក់ ប្រព្រឹត្តសេចក្ដីល្អ ៗ សេចក្ដីអាក្រក់និងសេចក្ដីល្អទាំងពីរនេះ ជារបស់ដែលបុគ្គលអាចនឹងលះនឹងបំពេញឲ្យមានបាន ៗ ព្រះបរមគ្រូសាស្ដាចារ្យបានត្រាស់ទុកថា "នៃភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរលះអកុសលចេញចុះ, ព្រោះបុគ្គលអាចនឹងលះអកុសលបាន, បើសិនជាបុគ្គលមិនអាចនឹងលះអកុសលបានទេ តថាគតក៏មិនអាចនឹងប្រៀនប្រដៅឲ្យអ្នកទាំងឡាយលះអកុសលបានដែរ; មួយទៀត អកុសលនេះ បើបុគ្គលលះបានហើយ ប្រព្រឹត្តទៅដើម្បីមិនមែនជាប្រយោជន៍ ប្រព្រឹត្តទៅដើម្បីសេចក្ដីទុក្ខវិញ តថាគតក៏មិនប្រៀនប្រដៅអ្នកទាំងឡាយឲ្យលះ

អកុសលដែរ; តែអកុសលនេះបុគ្គលអាចនឹងលះបាន កាលបើលះបានហើយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍និងសេចក្តីសុខ ទើបតថាគតប្រដៅអ្នកទាំងឡាយឲ្យលះអកុសល" ដូច្នេះ នេះជាបហានកិច្ច គឺកិច្ចដែលគួរលះ ។ សូម្បីកុសលការនាកិច្ចដែលគួរបំរើន ក៏អាចធ្វើបានដូចគ្នា ។ កិច្ចទាំងពីរនេះបុគ្គលអ្នកមានព្យាយាម អាចធ្វើឲ្យសម្រេចបាន ។ មនុស្សអ្នកមានព្យាយាមខំប្រឹងប្រែងធ្វើការងារ ដែលប្រាសចាកទោស បានទ្រព្យមកហើយ រមែងបានទទួលប្រយោជន៍អំពីភោគទ្រព្យ៥យ៉ាងគឺ:

១.– បំពេញខ្លួននឹងមាតាបិតា បុត្រភរិយាបាវព្រាវឲ្យជាសុខ;

២.– បំពេញមិត្តសំឡាញ់ឲ្យជាសុខ;

៣.– បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ;

៤.– ធ្វើពលី ៥ យ៉ាងគឺ: ក)– សង្គ្រោះញាតិ, ខ)– ទទួលភ្ញៀវ, គ) ធ្វើបុណ្យទក្ខិណាឲ្យដល់អ្នកស្លាប់, ឃ)– ថ្វាយពន្ធដារដល់រាជការផែនដីសូម្បីសង្គ្រោះដល់ប្រទេសជាតិ ឬលះទ្រព្យទំនុកបំរុងប្រទេសជាតិដើម្បីសេចក្តីចំរើនស្ថាពរ ចាត់ជារដ្ឋពលីអនុលោមចូលក្នុងខនេះ; ង)– ធ្វើបុណ្យទក្ខិណផលផ្សាយដល់ទេវតា ។

៥.– បរិច្ចាគទានដល់សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ ។

សាធុជន បពិត្រសប្បុរសទាំងឡាយ ថ្ងៃនិងយប់តែងតែកន្លងទៅ មិនមែនយប់នឹងថ្ងៃគ្រាន់តែកន្លងទៅប៉ុណ្ណោះទេ កាលវេលាដែលកន្លងទៅកន្លងទៅនេះ តែងស៊ីលេបនូវអាយុនិងសត្វទាំងឡាយ

ឲ្យដកទ្រូងទ្រោមបែកធ្លាយទៅផង, កាលបើយ៉ាងនេះ កិច្ចណាដែលគួរធ្វើ ត្រូវប្រញាប់ប្រញាល់ធ្វើឲ្យហើយទៅ កុំរញករញ៉ូវនឹងចាំពេលវេលាឡើយ ចូរប្រារព្ធសេចក្ដីព្យាយាមដែលនឹងនាំខ្លួនទៅកាន់សេចក្ដីសុខចំរើន; សមដូចពុទ្ធភាសិតថា អជ្ជេវ កិច្ចមាតប្បំ ដូច្នេះជាដើម (ប្រែថា, "បុគ្គលគួរធ្វើសេចក្ដីព្យាយាមក្នុងថ្ងៃនេះឲ្យហើយ អ្នកណាហ្នឹងដឹងថា សេចក្ដីស្លាប់នឹងមានមកក្នុងថ្ងៃស្អែក សេចក្ដីជៀសវាងឲ្យផុតអំពីមច្ចុមារមិនមានឡើយ" ។ បណ្ឌិតទាំងឡាយហៅបុគ្គលអ្នកមានសេចក្ដីព្យាយាមមិនខ្ជិល ទាំងកណ្ដាលថ្ងៃនឹងកណ្ដាលយប់ ថាជាអ្នកមានរាត្រីមួយ ៗ សុទ្ធតែចំរើន ។ កាលបើសាធុជនអ្នកមានប្រាជ្ញាញាណ ឃើញទោសនៃសេចក្ដីខ្ជិលច្រអូស នឹងឃើញអានិសង្សនៃសេចក្ដីព្យាយាម ដោយសភាពជាធម៌ដ៏ក្សេមប្រាសចាកភ័យដូច្នេះហើយ គួរតែបំបរបង់នូវសេចក្ដីខ្ជិលច្រអូសទ្រមក់ដែលបែបតាំងនៅក្នុងសន្ដានឲ្យអន្តរធានទៅ ហើយប្រញាប់ប្រញាល់ប្រារព្ធសេចក្ដីព្យាយាមក្នុងការងារដែលប្រាសចាកទោស រហូតដល់បានឃើញនូវប្រយោជន៍ក្នុងលោកទាំងពីរ ទាំងបានឈ្មោះថា ធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ,សមដោយភាសិតបរិយាយ ដែលបានលើកឡើងតាំងទុកក្នុងខាងដើមថា: កោសជ្ជំ ភយតោ ទិស្វា ។ល។ ឯសា ពុទ្ធានុសាសនី ។ អាត្មាភាពសំដែងមកក្នុងវិរិយារម្ភកថាក៏ចប់ដោយសង្ខេបតាមកាលវេលាតែប៉ុណ្ណោះ ។ ឯវំ ។

ពុទ្ធបរិស័ទគឺអ្នកណា

# យុនបណ្ឌុរក្ស ប៊ុ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ

*រៀបរៀង*

(ត-ចប់)

---

## សេចក្ដីអធិប្បាយអំពីអរិយសច្ច[១]

## ដោយសង្ខេប

១— ទុក្ខអរិយសច្ច *ពោលដោយខ្លី សំដៅយកខន្ធទាំងប្រាំ ទាំង៥ គឺសេចក្ដីប្រកាន់មាំថា រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ជារបស់ខ្លួន ។*

២— សមុទយអរិយសច្ច *សំដៅយកតណ្ហាដែលប្រែថា "សេចក្ដីប្រាថ្នា" ។ តណ្ហានេះជាដើមហេតុធ្វើឲ្យមនុស្សសត្វកើតហើយស្លាប់ៗ ហើយកើតទៀត មិនចេះផុត ។ ធ្វើឲ្យមនុស្សជាបុថុជ្ជនគឺអ្នកក្រាស់ដោយកិលេស ។ មនុស្សដែលនៅមានតណ្ហាសេចក្ដីប្រាថ្នាដរាបណា ក៏មិនដល់នូវទីរលត់ទុក្ខដរាបនោះ ប្រៀបដូចនៅមានភ្លើងគឺហេតុដរាបណា*

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា លេខ ម. ១២ និងច្បាប់អរិយសច្ចជាពុទ្ធភាសិតរបស់លោកគ្រូ ប៉ាង - ខាត់ ក្នុងកម្ពុជសុរិយាឆ្នាំ ១៩៤៥ និងច្បាប់សៀវភៅឈ្មោះអរិយសច្ច គីរី លេខ ម. ៥៣៣ ។

ផលគឺការក្តៅ ក៏នៅមានដកបនោះ ។ តណ្ហាមាន ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

៣– និរោធអរិយសច្ច សំដៅយកការរលត់តណ្ហាអស់ គឺបាន ដល់ព្រះនិព្វាន ។

៤– មគ្គអរិយសច្ច សំដៅយកមគ្គមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជា ផ្លូវប្រតិបត្តិឲ្យបានដល់នូវទីរលត់ទុក្ខគឺព្រះនិព្វាន ។

## ហេតុផលរបស់អរិយសច្ច

ទុក្ខ ជាផលរបស់សមុទ័យ។ ជាហេតុរបស់ទុក្ខ ។ និរោធ ជាផលរបស់ មគ្គ។ ជាហេតុរបស់ និរោធ ។

## កិច្ចដែលត្រូវធ្វើក្នុងអរិយសច្ចមាន ៤ [១]

១– ទុក្ខ ជាបរិញ្ញាតព្វកិច្ច គឺត្រូវកំណត់ដឹង

២– សមុទ័យ ជាបហាតព្វកិច្ច គឺត្រូវលះបង់ចេញ

៣– និរោធ ជាសច្ឆិកាតព្វកិច្ច គឺត្រូវធ្វើឲ្យជាក់ច្បាស់

៤– មគ្គ ជាភាវេតព្វកិច្ច គឺត្រូវធ្វើឲ្យកើតមានឡើង ។

កិច្ចក្នុងអរិយសច្ចទាំង ៤ នេះ រួមឲ្យខ្លីមក នៅតែត្រឹម ២ យ៉ាងគឺ លះបង់សមុទ័យ ១ ចំរើនមគ្គ ១ ។

---

១ កិច្ច ៤ នេះ គុណនឹងមគ្គ ៤ ទៅជា ១៦ ហៅថា សោឡសកិច្ច ។

## បរិវដ្តក្នុងអរិយសច្ច

បរិវដ្ត ប្រែថា "ញាណជាគ្រឿងវិលទៅ" សំដៅយកញាណទាំង ៣ គឺ សច្ចញាណ ១ កិច្ចញាណ ១ កតញ្ញាណ ១ ។

១ – ប្រាជ្ញាដឹងថា នេះទុក្ខ, នេះហេតុឲ្យកើតទុក្ខ, នេះសេចក្តីរលត់ទុក្ខ, នេះផ្លូវឲ្យដល់ទូវសេចក្តីរលត់ទុក្ខ ហៅថា សច្ចញាណ ប្រែថា ប្រាជ្ញាដឹងរបស់ពិត ។

២ – ប្រាជ្ញាដឹងថា ទុក្ខនេះគួរកំណត់ដឹង, សមុទ័យនេះគួរលះបង់, និរោធនេះគួរធ្វើឲ្យច្បាស់, មគ្គនេះគួរធ្វើឲ្យកើតមាន ហៅថា កិច្ចញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលគួរធ្វើ ។

៣ – ប្រាជ្ញាដឹងថា ទុក្ខនេះអាត្មាកំណត់ដឹងហើយ, សមុទ័យនេះអាត្មាលះបង់ហើយ, និរោធនេះអាត្មាធ្វើឲ្យច្បាស់ហើយ, មគ្គនេះអាត្មាធ្វើឲ្យកើតមានហើយ ហៅថា កតញ្ញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលធ្វើស្រេចហើយ ។

ញាណទាំង ៣ នេះ ប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ ត្រូវជាអាការ ១២ (៤ × ៣ = ១២) ។

## អត្ថក្នុងអរិយសច្ច ១៦

### ទុក្ខមានអត្ថ ៤

១.— បីឡនត្ថ ប្រែថា បៀតបៀន

២.— សង្ខតត្ថ ប្រែថា ត្រូវបច្ច័យប្រជុំតាក់តែង

៣.— សន្តាបត្ថ " ក្តៅក្រហាយ

៤.— វិបរិណាមត្ថ " ប្រែប្រួល ។

សមុទ័យមានអត្ថ ៤

១.— អាយុហនត្ថ ប្រែថា ឲ្យកើតកងទុក្ខ

២.— និទានត្ថ " ជាហេតុនៃទុក្ខ

៣.— សំយោគត្ថ " ប្រកបសត្វទុកក្នុងសង្សារទុក្ខ

៤.— បលិពោធត្ថ " ឃុំខាំងសត្វទុកក្នុងគុកគឺសង្សារទុក្ខ ។

និរោធមានអត្ថ ៤

១.— និស្សរណត្ថ ប្រែថា ជួយឲ្យចេញចាកចំណង(កិលេស)

២.— វិវេកត្ថ[១] " ស្ងាត់ចាកកិលេស

៣.— អសង្ខតត្ថ " បច្ច័យតាក់តែងមិនបាន

៤.— អមតត្ថ " ជាអម្រឹតរស (មិនចេះស្លាប់) ។

មគ្គមានអត្ថ ៤

១.— និយ្យានត្ថ ប្រែថា ជញ្ជូនសត្វចេញចាកវដ្តសង្សារ

---

១ ច្បាប់អរិយសច្ចកថា ថា: អបលិពោធត្ថោ មានអត្ថថា រកកង្វល់រវល់មិនមាន ។

២.— ហេតុត្ថ ប្រែថា ជាហេតុនៃព្រះនិព្វាន

៣.— ទស្សនត្ថ[១] " ឃើញព្រះនិព្វាន

៤.— អធិបតេយ្យត្ថ " ជាអធិបតីក្នុងវិមុត្តិញាណទស្សនៈ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់ថាចតុរារិយសច្ចជាគោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនាហើយ ត្រូវតែត្រិះរិះជ្រើសរើសរកផ្លូវប្រតិបត្តិឲ្យឃើញថាផ្លូវណាជា ៖

## គោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងពុទ្ធសាសនា

កាលពីជំនាន់បុរាណ ដែលមិនទាន់មានព្រះពុទ្ធជាម្ចាស់ក្នុងលោក បណ្ដាមនុស្សទាំងអស់ធ្លាប់ស្គាល់សុខទុក្ខមកហើយ តែងស្អប់ខ្ពើមទុក្ខណាស់ មិនចង់បានទុក្ខសោះ ស្រឡាញ់តែសុខ ចង់បានតែសុខមួយយ៉ាងប៉ុណ្ណោះ ម្ល៉ោះហើយក៏កើតគំនិតរិះគិតរកផ្លូវប្រតិបត្តិដើម្បីចៀសវាងឲ្យផុតពីទុក្ខ ធ្វើឲ្យកើតសុខដល់ខ្លួន ប៉ុន្តែប្រតិបត្តិមិនត្រូវត្រង់ផ្លូវរំលត់ទុក្ខ ក៏គ្រាន់តែបានស្រាកស្រាន្តស្ងប់ទុក្ខក្នុងកាលខ្លះ លុះអស់អំណាចកម្លាំងធម៌នោះហើយ ក៏ត្រឡប់ជាកើតទុក្ខឡើងវិញដដែល ទទួលសោយទុក្ខអស់កាលវែងឆ្ងាយតទៅមុខទៀត មិនរួចផុត ព្រោះតែមិនបានដឹងអរិយសច្ច ៤ ដូចជាអាឡារតាបសនឹងឧទកតាបសចំរើនឈាន

១ និទស្សនត្ថោ អធិប្បាយថា សំដែងចេញ ។

ឲ្យបានផលទៅកើតនៅនាស្ថានព្រហ្ម ដោយសំគាល់ខុសថា ស្ថានព្រហ្មជាទីផុតទុក្ខ ជាទីរលត់ទុក្ខអស់ ។ ព្រះពុទ្ធជាម្ចាស់នៃយើង កាលព្រះអង្គកំពុងតែស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខ មុនបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ធ្លាប់បានចូលទៅនៅសិក្សាលទ្ធិធម៌ក្នុងសំណាក់តាបសទាំង ២ រូបនោះដែរ ប៉ុន្តែទ្រង់ជ្រាបថាធម៌នេះមិនមែនជាផ្លូវប្រតិបត្តិឲ្យផុតទុក្ខទេ ទើបទ្រង់យាងចេញពីសំណាក់តាបសទាំង ២ រូបនេះ ទៅស្វែងរកផ្លូវប្រតិបត្តិដោយវិធីផ្សេង ៗ ទៀត ។

កាលដែលព្រះបរមសាស្តាបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធថ្មីៗ ផុតពី ៤៩ ថ្ងៃមក ព្រះអង្គទ្រង់ត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រ (អរិយសច្ច ៤) និងអនត្តលក្ខណសូត្រ (ព្រះត្រៃលក្ខណ៍) មុនធម៌ទាំងអស់ ប្រោសភិក្ខុបញ្ចវគ្គិយ (៥ រូប) មុនពុទ្ធបរិស័ទទាំងពួងនៅនាព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី ។

សេចក្តីខាងដើមនៃព្រះធម្មចក្កប្បវត្តនសូត្រ ទ្រង់ត្រាស់ប្រារព្ធអំពីផ្លូវប្រតិបត្តិ ៣ ប្រការថា ម្នាលភិក្ខុទាំងឡាយ ផ្លូវប្រតិបត្តិ ១ ធូរថយពេក ហៅ កាមសុខល្លិកានុយោគ ប្រែថា "ការប្រកបខ្លួនឲ្យទទឹកជោកទៅដោយសេចក្តីសុខក្នុងកាម," ផ្លូវប្រតិបត្តិ ១ ទៀតតឹងរឹងហួសពេក ហៅ អត្តកិលមថានុយោគ ប្រែថា "ការប្រកបខ្លួនទុកក្នុងសេចក្តីលំបាក" សំដៅយកការប្រតិបត្តិដែលពួកជនខ្លះ ទំព្យាយាមទូន្មានខ្លួនដោយវិធី

ផ្សេងៗ មានកាំងភ្លើង, ហាលថ្ងៃជាដើម ដើម្បីឲ្យបានផុតទុក្ខព្រួយនឹងឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នា; ផ្លូវប្រពោកនឹងផ្លូវតឹងពេកទាំង ២ ប្រការនេះ តថាគតបានប្រតិបត្តិរួចមកហើយ ដឹងថាជាផ្លូវឥតផលប្រយោជន៍ ជាផ្លូវដឹកនាំក្រក់លាមកថោកទាប អ្នកទាំងឡាយមិនត្រូវប្រតិបត្តិតាមផ្លូវទាំង ២ យ៉ាងនេះទេ ។

ម្នាលភិក្ខុទាំងឡាយ នៅមានផ្លូវប្រតិបត្តិ ១ ទៀត ជាផ្លូវប្រតិបត្តិយ៉ាងកណ្ដាល មិនប្រពោក មិនតឹងពេក ជាផ្លូវប្រតិបត្តិឲ្យដល់នូវទីរលត់ទុក្ខពិតប្រាកដ ជាផ្លូវដ៏ប្រសើរមានអង្គ ៨ (អដ្ឋង្គិកមគ្គ) ជាផ្លូវដែលតថាគតបានប្រតិបត្តិរួចមកហើយ តថាគតបានត្រាស់ដឹងអរិយសច្ច ៤ (របស់ពិត ៤ យ៉ាង) ដោយសារផ្លូវនេះ អ្នកទាំងឡាយត្រូវប្រតិបត្តិធម៌តាមផ្លូវកណ្ដាលនេះចុះ ដែលជាផ្លូវមានឈ្មោះថា មជ្ឈិមាបដិបទា ប្រែថា "សេចក្ដីប្រតិបត្តិជាយ៉ាងកណ្ដាល" សំដៅយកការដើរទៅតាមគន្លងផ្លូវយ៉ាងកណ្ដាល ជាផ្លូវទៅកាន់ទីរលត់ទុក្ខ ។

ផ្លូវកណ្ដាលដែលឈ្មោះថា មជ្ឈិមាបដិបទា នេះមានអង្គ ៨ (អដ្ឋង្គិកមគ្គ[1]) គឺ :

១_ សម្មាទិដ្ឋិ សេចក្ដីឃើញត្រូវ

២_ សម្មាសង្កប្ប សេចក្ដីត្រិះរិះត្រូវ

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា របស់ពុទ្ធសាសនបណ្ឌិត្យសោ។ ម. ១២ ។

៣– សម្មាវាចា　　　　វាចាត្រូវ

៤ – សម្មាកម្មន្ត　　　　ការងារត្រូវ

៥– សម្មាអាជីវៈ　　　　ចិញ្ចឹមជីវិតត្រូវ

៦– សម្មាវាយាម　　　　ព្យាយាមត្រូវ

៧– សម្មាសតិ　　　　រលឹកត្រូវ

៨– សម្មាសមាធិ　　　　តាំងចិត្តមាំត្រូវ ។

អង្គទាំង ៨ នេះ លុះតែមានព្រមជាមួយគ្នា គ្រប់ទាំង ៨ រួមចូលគ្នាជាកំឡាំងតែមួយ ទើបហៅថា មគ្គ ឬអរិយមគ្គ ឬមជ្ឈិមាបដិបទា, បើញែកចេញឲ្យដាច់ពីគ្នាតែអង្គមួយ ៗ វិញ មិនហៅថា មគ្គទេ គ្រាន់តែហៅត្រឹមចំណែកអង្គមួយ ៗ តាមឈ្មោះអង្គនោះ ៗ ប៉ុណ្ណោះ ។

មគ្គមានឈ្មោះ ៤ យ៉ាង តាមកំឡាំងដែលអាចលះកិលេសបាន គឺ

១ – សោតាបត្តិមគ្គ　ជាគូនឹង　សោតាបត្តិផល

២ – សកទាគាមិមគ្គ　–　សកទាគាមិផល

៣– អនាគាមិមគ្គ　–　អនាគាមិផល

៤ – អរហត្តមគ្គ　–　អរហត្តផល ។

មគ្គ ៤ ផល ៤ នេះ ជាឈ្មោះរបស់ចិត្ត ។ អ្នកមានមគ្គចិត្តនឹងផលចិត្តយ៉ាងនេះ ហៅថា អ្នកបានសម្រេចមគ្គផល ។

ការប្រតិបត្តិធម៌គ្រប់ជាន់ មានមជ្ឈិមាបដិបទាជាបង្គោល ។ មជ្ឈិមាបដិបទាជាទីប្រជុំចុះនៃការប្រតិបត្តិធម៌ទាំងអស់ ក្នុងព្រះពុទ្ធសាសនាទាំងមូល ។ មជ្ឈិមាបដិបទាជាក្រសែនៃព្រះនិព្វាន, ជាផ្លូវដើរនៃចិត្ត, មិនមែនជាផ្លូវសម្រាប់ដើរដោយជើងទេ ។

មជ្ឈិមាបដិបទាជាធម៌សម្រាប់មនុស្សគ្រប់រូប មិនមែនជាធម៌ខ្ពស់ហួសផុតវិស័យរបស់មនុស្សឡើយ, មិនមែនជាធម៌ធ្វើឲ្យមនុស្សទន់ខ្សោយ ឬធ្វើឲ្យខ្ជិលច្រអូស ឲ្យចាលចាញ់សេចក្ដីទុក្ខដែលខ្លួនត្រូវអត់ធន់នោះទេ, ជាធម៌សម្រាប់មនុស្សអ្នកស្អប់ខ្ពើមទុក្ខ ហើយចង់បានសុខពិតប្រាកដ, ជាធម៌យ៉ាងកណ្ដាល មានថ្នាក់ខ្ពស់ទាបតាមខ្នាតរបស់មនុស្សបុថុជ្ជនគ្រប់រូបក្នុងលោកនេះ មិនមែនជាធម៌សម្រាប់តែព្រះអរិយបុគ្គលមួយចំពូកប្រតិបត្តិប៉ុណ្ណោះទេ ដ្បិតថា បើមនុស្សបុថុជ្ជនមិនប្រតិបត្តិតាមមជ្ឈិមាបដិបទានេះហើយ ធ្វើម្ដេចនឹងក្លាយខ្លួនទៅជាព្រះអរិយបុគ្គលគឺអ្នកបានសម្រេចមគ្គ ៤ ផល ៤ កើត ហេតុនេះបានជាតាត់មជ្ឈិមាបដិបទាថា ជាគោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងព្រះពុទ្ធសាសនា ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់នូវមជ្ឈិមាបដិបទាជាគោលដ៏សំខាន់នៃការប្រតិបត្តិធម៌ហើយ ត្រូវតែពិចារណាដេញដោលរកឲ្យឃើញផលនៃការប្រតិបត្តិធម៌ថា ផលដូចម្ដេច ដែលជា ៖

# ផលប្រយោជន៍យ៉ាងខ្ពស់បំផុតនៃការប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា (១)

ក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា បានសំដែងបញ្ជាក់ អំពីផលប្រយោជន៍នៃការប្រតិបត្តិធម៌ ដោយអនេកបរិយាយ ប៉ុន្តែផលទាំងអស់នោះ បើបំប្រួញឲ្យតិចមក នៅមានតែត្រឹម ២ យ៉ាងគឺ ផលជាលោកិយ ១ ផលជាលោកុត្តរ ១ ។

## ផលជាលោកិយ

ក្នុងទីនេះ សូមបរិយាយអំពីផលជាលោកិយមុន (១). អ្នកប្រតិបត្តិធម៌តាមត្រសែនៃមជ្ឈិមាបដិបទា ដូចបានរៀបរាប់ខាងដើមហើយនោះ រមែងបានផលប្រយោជន៍យ៉ាងវិសេសក្នុងវេលាកំពុងតែប្រតិបត្តិធម៌ មិនបង្អង់ចាំពេលណាទើបបានផលទេ (អកាលិកោ) ជាធម៌ឲ្យផលពុំមានកាលខាន់ គឺថា មជ្ឈិមាបដិបទាធ្វើអ្នកប្រតិបត្តិតាមឲ្យជាមនុស្សមានហេតុផលជាគោលការ, ធ្វើឲ្យជាអ្នកដាច់ស្រេចក្នុងចិត្ត, ធ្វើឲ្យជាអ្នកឈ្នះខ្លួនឯងបាន, ធ្វើឲ្យជាអ្នកបង្ក្រាប់បញ្ជាខ្លួនឯងបាន, ធ្វើឲ្យជាអ្នកមានសេចក្តីប្រាថ្នាត្រឹមត្រូវ, ធ្វើឲ្យជាអ្នកទៀងទាត់ត្រង់ផ្លូវ, ធ្វើឲ្យជាអ្នកមានកាយកម្ម, វចីកម្ម និងការចិញ្ចឹមជីវិត ប្រាសចាកទុក្ខក្តៅក្រហាយគ្រប់ប្រការ, ធ្វើឲ្យជាអ្នកមានព្យាយាម, មានសេចក្តីក្លាហាន មានសេចក្តី

---

១ ស្រង់ចាកច្បាប់ពុទ្ធសាសនាសៀម លេខ ម. ៤៣៥ ទំព័រ.៥១៧... ។

ចេះដឹង ទាំងឲ្យមានសេចក្ដីទៀងទាត់ក្នុងចិត្ត ល្មមឲ្យជីវិតរបស់ខ្លួនមានរបៀបរៀបរយ ត្រូវដល់ឋានៈរបស់ធម៌ដែលខ្លួនប្រតិបត្តិ ។

កាលមនុស្សបានប្រតិបត្តិធម៌ត្រឹមត្រូវតាមមជ្ឈិមាបដិបទា ដែលមានសម្មាទិដ្ឋិ ជាប្រធាន ជាមេនាំអាទិហើយ ក៏រមែងបានផលអាចឲ្យកើតអង្គមគ្គ ៧ ខាងចុងៗ គ្នាតាមលំដាប់ភ្ជាមៗ មិនរង់ចាំកាលណាទេ ដូចជាអ្នកមាន ៖

១– សេចក្ដីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) ការចូលចិត្តត្រឹមត្រូវតាមហេតុផល ក៏ជាផ្លូវឲ្យកើត ៖

២– សេចក្ដីត្រិះរិះត្រូវ (សម្មាសង្កប្ប); សេចក្ដីត្រិះរិះត្រូវធ្វើឲ្យកើត ៖

៣– វាចាត្រូវ (សម្មាវាចា)

៤– ការងារត្រូវ (សម្មាកម្មន្ត)

៥– ការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវ)

៦– ព្យាយាមត្រូវ (សម្មាវាយាម)

៧– រលឹកត្រូវ (សម្មាសតិ)

៨– តាំងចិត្តមាំត្រូវ (សម្មាសមាធិ) ។

កាលបើអង្គមគ្គជាហេតុកើតមានយ៉ាងនេះហើយ ការលះកិលេស

នោះៗ បានជាផល ក៏កើតមានឡើងក្នុងខណៈនៃមគ្គនោះៗ ដែរ ប៉ុន្តែជាមគ្គនៅទន់ខ្សោយ នៅស្តើងស្តួច មិនទាន់ខ្លាំងក្លា មិនទាន់ពេញលេញ ហៅថាអរិយមគ្គមិនទាន់បាន គ្រាន់តែអាចលះកិលេសបំពួកខ្លះបាន តាមកំឡាំងនៃមគ្គជាលោកិយ ឲ្យបានផលជាលោកិយប៉ុណ្ណោះ ៗ

បណ្តាផលជាលោកិយទាំងអស់ សំដៅយកត្រង់ការអស់កិលេសបំពួកខ្លះនោះ ថាជាផលប្រសើរបំផុតលើសផលលោកិយនានា មានផលសោយសុខសម្បត្តិក្នុងស្ថានមនុស្សនិងស្ថានសួគ៌ជាដើម ៗ

## ផលជាលោកុត្តរ

មគ្គជាលោកិយដូចមាននិយាយរួចហើយនោះ ជាគោលនៃការគ្រប់គ្រងជីវិតរបស់អ្នកប្រតិបត្តិឲ្យប្រព្រឹត្តទៅរៀបរយ ឲ្យបានសុខសប្បាយរាល់ៗថ្ងៃ ហៅថា អ្នកបានផលជាលោកិយ ៗ

ផលជាលោកិយនេះ កាលបើគេអប់រំអង្គមគ្គ ឲ្យចាស់ក្លាដល់កំរិតហើយ អាចក្លាយទៅជា "អរិយផល" ដែលកើតពីអរិយមគ្គបាន ដូចសេចក្តីអធិប្បាយ ដោយសង្ខេបតទៅនេះ ៖

អ្នកប្រតិបត្តិធម៌តាមលំអាននៃមជ្ឈិមាបដិបទា ជាលោកិយហើយ បានព្យាយាមអប់រំអង្គមគ្គទាំង ៨ ឲ្យមានកម្លាំងពេញទីតាមវិធីនៃការប្រតិបត្តិធម៌ ព្រមព្រៀងគ្នាជាកម្លាំងតែ ១ ហើយ ហៅថា "អរិយមគ្គ" ៗ នេះ អាចកំចាត់កិលេស ឬ សំយោជន៍យ៉ាងល្អិតបំផុតដែលត្រាំជាប់ស្អិត

នៅក្នុងចិត្តឲ្យលេចទៅតាមចំណែកនៃកម្លាំងអរិយមគ្គដែលខ្លួនអប់រំបាន ។ ផលដែលកើតមានឡើង អំពីកិរិយាលះបង់កិលេសបាននេះ ហៅថា "អរិយផល" ។ អរិយមគ្គដែលចាស់ក្លាដល់កំរិតអាចកំចាត់កិលេសក្នុងចិត្តបានត្រឹមណា ក៏មានឈ្មោះហៅតាមជាន់នៃការលះកិលេសរបស់ខ្លួនបានត្រឹមណោះថា សោតាបត្តិមគ្គ, សកទាគាមិមគ្គ អនាគាមិមគ្គ, អរហត្តមគ្គ ។ អរិយផលក៏មានជាគូនឹងអរិយមគ្គគ្រប់ៗមគ្គដែរ គឺសោ-តាបត្តិផល, សកទាគាមិផល, អនាគាមិផល, អរហត្តផល, ហេតុនោះទើបកើតបានជាមគ្គ ៤ ផល ៤ ហៅកាត់ខ្លីថា "មគ្គផល" ។ អរិយមគ្គជាហេតុ អរិយផលជាផល ។ អរិយមគ្គដែលមានឈ្មោះផ្សេងគ្នាជា ៤ យ៉ាងនោះ ក៏ព្រោះកំចាត់កិលេសបានច្រើនតិចជាងគ្នា (១) ។ ឱកាសបើកឲ្យអង្គមគ្គប្រជុំគ្នាជាអរិយមគ្គបានកាលណា ការកាត់សំយោជន៍ក៏កើតមានឡើងក្នុងកាលណោះមួយរំពេច ។ ឱកាសនេះមិនកំណត់កាលទេ (អកាលិកោ) កើតមានឡើងក្នុងខណៈ ដែលចិត្តមូលជាអារម្មណ៍តែមួយដោយឆាប់រហ័ស ដូចអ្នកខ្លះស្ដាប់ទេសន៍បានសម្រេចមគ្គផលនៅទីនោះភ្លាម ក៏មាន (ខិប្បាភិញ្ញា), ដោយសេចក្ដីព្យាយាមដ៏ខ្លាំងក្លា ដូចព្រះយោគាវចរខំចំរើនភាវនារឿយៗ រាល់ថ្ងៃទាល់តែបានសម្រេចមគ្គផល ក៏មាន (ទន្ធាភិញ្ញា) ។

---

១ អរិយមគ្គណា កំចាត់កិលេសអ្វីខ្លះ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា លេខ ម. ១២ ។

អ្នកប្រតិបត្តិធម៌ហើយបានសម្រេចលោកុត្តរផល ជាផលជាន់ខ្ពស់បំផុតយ៉ាងនេះហើយ ឈ្មោះថាជាអ្នកបានដល់ព្រះនិព្វានជាស្ថានរលត់ទុក្ខទាំងអស់ ឈ្មោះថាជាអ្នកប្រតិបត្តិធម៌ត្រឹមត្រូវតាមវគ្គបំណងនៃព្រះពុទ្ធសាសនាពិតប្រាកដ ព្រោះព្រះពុទ្ធសាសនាទាំងមូល មានចំណុចជាទីបំផុតត្រង់មគ្គ ៤ ផល ៤ និព្វាន ១ រួមជា ៩ ដែលហៅថាព្រះនព្វលោកុត្តរធម៌ ។

## សេចក្ដីបញ្ចប់

មនុស្សជាជាតិអ្វីក៏ដោយ ប្រុសឬស្រី ក្មេងឬចាស់ ដែលជាអ្នកកាន់ពុទ្ធសាសនា បាននាមបញ្ញត្តិថា "ពុទ្ធបរិស័ទ" ហើយ ត្រូវពិចារណាឲ្យយល់ច្បាស់ដោយគំនិតប្រាជ្ញារបស់ខ្លួនថា៖

ព្រះពុទ្ធសាសនា ជាសាសនាទៀងទាត់ណាស់ គ្មានសារីកណាអាចលុបលាង ឬ កែប្រែដូចជាច្បាប់សម្រាប់ប្រទេសមួយៗ បានទេ, ជាសាសនាមិនទទួលពាក្យអង្វរករបន់ស្រន់របស់អ្នកណាសោះ, ជាសាសនាមិនទទួលកប់រងទុក្ខទោសជួសអ្នកណាសោះឡើយ, ជាសាសនាចង្អុលហេតុផលយ៉ាងជាក់ខាត ។

ព្រះពុទ្ធសាសនាប្រៀបដូចទូក ពួកពុទ្ធបរិស័ទប្រៀបដូចអ្នកជិះ ៗ ទូកលឿនក្ដី មិនលឿនក្ដី នៅត្រង់ឬវៀចវេក្ដី ក៏ស្រេចតែលើខ្លួនអ្នកជិះ ៗ បើទូកបែកធ្លុះធ្លាយ ត្រូវតែអ្នកជិះជួសជុលបិទភ្ជិតខ្លួនឯង បើមិនបិទទេ

ទុក្ខកំលំបាក ខ្លួនអ្នកដឹងកំលង់ទឹកស្លាប់ក្នុងលទ្ធ គ្មានហៅអ្នកណាឲ្យជួយខ្លួនបានទេ ។

ពួកពុទ្ធបរិស័ទ មិនត្រូវតាំងចិត្តផ្អែកផ្ទេរទៅលើព្រះពុទ្ធអង្គដោយនឹកគាំងថា "ព្រះពុទ្ធអង្គនឹងមកជួយដកដៃយកយើងខ្លួនឲ្យរួចពីទុក្ខទោស" ដូច្នេះឡើយ ត្រូវតែតាំងចិត្តជឿកម្មនិងផលរបស់កម្មជាយ៉ាងដាច់ខាតថា "កម្មល្អឲ្យផលជាសុខ កម្មអាក្រក់ឲ្យផលជាទុក្ខ អ្នកណាបានសុខឬបានទុក្ខ ក៏ព្រោះតែអ្នកនោះបានធ្វើកម្មល្អ ឬ អាក្រក់រួចមកហើយ គ្មានអ្នកណាអាចទទួលសុខទុក្ខជួសអ្នកណាបានទេ ប្រៀបដូចចោរលួចប្លន់គេ ៗ ចាប់ដាក់គុក គ្មានអ្នកណាទទួលទោសគុកជួសចោរនោះបានទេ សូម្បីតែអាពុកបង្កើតក៏ទទួលទោសជួសកូនមិនបានដែរ ។ សេចក្ដីបរិសុទ្ធនិងមិនបរិសុទ្ធចំពោះតែរូបមនុស្សម្នាក់ ៗ គ្មានអ្នកណាបរិសុទ្ធជួសអ្នកណាបាន ប្រៀបដូចអ្នករៀនចំណេះវិជ្ជាផងទាំពួង អ្នកណារៀន អ្នកនោះចេះ នឹងរៀនជួសគ្នា ឬនឹងចេះជួសគ្នាមិនកើត ។ ការរៀនជាកម្ម គឺហេតុ ការចេះដឹងជាផល ។"

ពួកពុទ្ធបរិស័ទបើជឿកម្មផលដូច្នេះហើយ ទើបបានប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្តបំណងរបស់ព្រះពុទ្ធសាសនា ។ បើមិនជឿកម្មផលទេ ចេះតែធ្វើបុណ្យឲ្យទានរក្សាសីលទាំងខ្លាក់ទាំងប៉ូង់ ព្រោះចិត្តចង់ឲ្យបានសុខ លុះមិនបានសុខដូចបំណង ផ្សិតប្រតិបត្តិខុសគន្លងធម៌ ក៏ទៅជា

ខំបន់ព្រះសំពះទេវតាឲ្យជួយខ្លួន កាលបើមិនឃើញព្រះ ឬ ទេវតាជួយ ក៏ត្រឡប់ជាខឹងស្អប់បន្ទោសព្រះ ឬ ទេវតាថាមិនជួយខ្លួនទៅវិញ ។

បណ្ដាយថាសភាវៈទាំងឡាយ (របស់កើតមានឯង) ដូចជាគេយកទឹកស្រោចភ្លើងៗតែងរលត់អស់ទៅ នេះជាទំនៀមទម្លាប់យ៉ាងទៀងទាត់របស់ធម្មតា គ្មានមនុស្សណាជាអ្នកសាងភ្លើង ឬទឹកដែលជាវត្ថុធម្មជាតិនោះឡើយ មានតែមនុស្សជាអ្នកដឹងទំនៀមនេះថា "បើគេយកទឹកស្រោចភ្លើង ៗ មុខជារលត់អស់មិនខាន" អ្នកដឹងយ៉ាងនេះចាត់ជាមនុស្សដឹងមុនគេ ហើយប្រាប់គ្នាតៗ មក ព្រះពុទ្ធអង្គក៏ដូច្នោះដែរ គឺព្រះអង្គបានជ្រាបរបស់ពិត (អរិយសច្ច) មុនគេ ព្រះអង្គមិនបានកសាងមគ្គទាំង ៨ ឡើងទេ ព្រះអង្គគ្រាន់តែបានស្វែងរកមគ្គឃើញមុនគេ ហើយប្រកាសប្រាប់អ្នកដែលចង់បានសុខ ឲ្យដើរទៅតាមអដ្ឋមគ្គទាំង ៨ នោះប៉ុណ្ណោះ (អក្ខាតារោ តថាគតា) ។

អដ្ឋមគ្គទាំង ៨ ប្រៀបដូចជាផ្លូវចល់ ១ ប្រកបដោយអដ្ឋគុណ ៨ យ៉ាងគឺ មានក្ដារបិទប្រកាសប្រាប់ដំណើរ (សម្មាទិដ្ឋិ), មិនវៀចវេរត្រង់ទៅកាន់ទីតាមប្រាថ្នា (សម្មាសង្កប្បៈ), មានគូស្លាមក្បោះ (សម្មាវាចា), មានម្លប់ឈើ (សម្មាកម្មន្ត), មានកន្លែងសំណាក់អាស្រ័យ (សម្មាអាជីវៈ), មានទីរកអាហារបាន (សម្មាវាយាម), មានការ

គ្រប់គ្រងអ្នកដំណើរ (សម្មាសតិ), មានសេចក្ដីសុខដល់អ្នកដំណើរ (សម្មាសមាធិ), អរិយមគ្គក៏មានអង្គជា ទាទី ៗ លួមសម្គួរឲ្យបានសម្រេចសេចក្ដីប្រាថ្នារបស់អ្នកប្រតិបត្តិដូចជាផ្លូវនោះដែរ ។

អង្គមគ្គទាំង ៨ នឹងដើរជួសគ្នាមិនបានទេ ព្រោះជាចំណែកចិត្ត មិនមែនជាចំណែករត្នដូចការលត់ភ្លើងដែលអាចជួយស្រោចជួសគ្នាបានទេ ។ ភ្លើងប្រៀបដូចសេចក្ដីទុក្ខក៏មែនហើយ ប៉ុន្តែភ្លើងជាចំណែករត្ន ការលត់ជាចំណែកកាយ ទើបអាចជួយលត់ជួសគ្នាបាន ។ ទុក្ខក្នុងទីនេះជាចំណែកចិត្តដែលមនុស្សម្នាក់ៗរូបដឹងឃើញដោយខ្លួនឯង (សន្ទិដ្ឋិកោ) ទើបធ្វើជួសគ្នាមិនបាន ប្រៀបដូចជាអ្នករៀន មិនអាចរៀនសូត្រចំណេះវិជ្ជាជួសគ្នាបានដូច្នោះដែរ ។

ព្រះពុទ្ធអង្គគ្រាន់តែជាអ្នកបានត្រាបរបស់ពិតដ៏ប្រសើរ (អរិយសច្ច ៤) មុនគេ ហើយទ្រង់ចង្អុលប្រាប់គេថា នេះហៅថាទុក្ខ (ទុក្ខអរិយសច្ច), នេះជាហេតុឲ្យកើតទុក្ខ (ទុក្ខសមុទយអរិយសច្ច), នេះជាសេចក្ដីរលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច), នេះជាផ្លូវដែលនឹងធ្វើអ្នកដំណើរឲ្យដល់នូវសេចក្ដីរលត់ទុក្ខ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច), ជាផ្លូវដែលធ្វើឲ្យមារទឹងសេនាមារតាមមិនទាន់, ជាផ្លូវដែលអ្នកទាំងឡាយត្រូវព្យាយាមដើរទៅដោយខ្លួនឯង ព្រះតថាគតទាំងឡាយគ្រាន់តែជា

អ្នកប្រាប់ផ្លូវប៉ុណ្ណោះទេ (អក្ខាតារោ តថាគតា) ។ មួយទៀត ព្រះតថាគតទាំងឡាយ មិនដែលទទួលពាក្យអង្វរករបន់ស្រន់របស់អ្នកណាឡើយ (សុទ្ធិអសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ) ។

ការប្រតិបត្តិធម៌

គឺជាការផ្លាស់ចិត្តអាក្រក់ឲ្យក្លាយទៅជាចិត្តល្អ,

ជាការធ្វើជីវិតឲ្យបានសុខស្រួល;

ជាការបំបាត់សេចក្ដីល្ងង់ខ្លៅ,

ជាការចេញចាកទុក្ខឈានទៅរកសុខ

សឹងមានព្រះនិព្វានជាទីដៅ ។

រឿងពុទ្ធបរិស័ទគឺអ្នកណា សង្ខេបប៉ុណ្ណោះ

---

# បញ្ញាសជាតក

## ភាគទី ២

បណ្ឌិតមហា ឈឹម - ស៊ុម សាស្ត្រាចារ្យ

នៅសាលាបាលីជាន់ខ្ពស់ បានឲ្យប្រែហើយពិនិត្យផ្ទៀងផ្ទាត់ដោយខ្លួនឯង

កាលដែលនៅជាភេទបព្វជិតពី ព.ស. ២៤៨៦, គ.ស. ១៩៤៣

តមក

---

## សុកមិត្តជាតក ទី ៩

(តចប់)

(និយាយអំពីដំណើរព្រាត់ប្រាស ព្រោះមានពៀរដោយយកកូនសត្វ)

លោកអាចារ្យ ឈឹម - ស៊ុម ក្រុមជំនុំព្រះត្រៃបិដក

ប្រែពីបាលី

ចំណែកខាងនាយសំពៅ ចង់រួមសំរាសជាមួយនឹងនាងទេវីនោះណាស់; តែដោយសេចក្តីអធិដ្ឋានរបស់ព្រះនាង នឹងតេជះសីលនៃព្រះស្វាមី ក៏នាយសំពៅហាក់ដូចជាក្តៅក្រហាយ មិនអាចប្រទុស្តបានឡើយ, ត្រឡប់ជាធ្វើសក្ការបូជាដូចជាទេវតាទៅវិញ ។ នាងទេវីនោះ តែងគោរពនមស្សការបូជាចំពោះទេវតាផ្សេងៗ ជានិច្ច ហើយនាងបួងសួងបន់ស្រន់ចន្ទទេវបុត្ត សុរិយទេវបុត្ត សក្កទេវរាជនឹងទេវធីតាមណិមេខលា ប្រាថ្នាថា ខ្ញុំសូមឲ្យបានឃើញព្រះរាជស្វាមីនៃខ្ញុំកុំខានឡើយ ។

កាលកន្លងទៅ ៧ ឆ្នាំ នាយសំពៅនោះព្រមទាំងព្រះនាងទេវីបាន ទៅដល់ក្រុងតក្កសិលា ហើយនាំយកគ្រឿងសក្ការបណ្ណាការទៅថ្វាយ ព្រះចៅក្រុងតក្កសិលានោះ ។ កាលបើនាយសំពៅនោះ នៅក្នុងក្រុងតក្កសិលា អស់វេលាពីរបីថ្ងៃ ក៏ក្រាបបង្គំលាព្រះរាជា សូមត្រឡប់វិញថា

អាបុច្ឆាមិ តំ ទេវ គមិស្សាមិ សរាណិជ្ជា
បិវំ តោ ឥធ វាសោវ គមិស្សាមិ សកាលយំ

សូមទានព្រះរាជតេជះដម្កល់លើត្បូង, ទូលព្រះបង្គំជាខ្ញុំសូម ក្រាបបង្គំលាទៅរកជួញប្រែងប្រទេសដទៃទៀត ដ្បិតទូល ព្រះបង្គំជាខ្ញុំមកនៅក្នុងទីនេះយូរណាស់ហើយ ។

ព្រះរាជាទ្រង់ព្រះសណ្តាប់ពាក្យនាយសំពៅនោះហើយ ក៏ទ្រង់ ឃាត់ថា

បស្សាហិ ភោ មហាគាវ ឆប្គីគេ សុវាទិតេ
ឯករត្តឹ វសិត្វាន បាតោ គច្ឆសិ នាវិក

ម្នាលនាយសំពៅដ៏ចំរើន, ចូរអ្នកនៅចាំមើលមហោស្រព មួយយប់សិន ស្អែកសឹមអ្នកចេញសំពៅទៅពីព្រឹកចុះ ។

ព្រះរាជាទ្រង់ត្រាស់ដូច្នេះហើយ ទ្រង់ធ្វើសក្ការៈរាប់អានចំពោះ នាយសំពៅនោះ ដល់ព្រះអាទិត្យអស្តង្គត នាយសំពៅក៏ក្រាបបង្គំលា ព្រះរាជាទៀតថា សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំជា

អ្នកជំនួញ ចង់មើលមហោស្រពណាស់ដែរ, ចង់នៅក្នុងទីនេះមួយយប់ទៀត, ប៉ុន្តែជាប់ចំពាក់ទីនការរក្សាសំពៅ ព្រោះព្រួយបារម្ភដល់ទ្រព្យសម្បត្តិក្នុងសំពៅ ខ្លាចក្រែងចោរធ្វើឲ្យអន្តរាយ ។ ព្រះរាជាទើបទ្រង់ត្រាស់នឹងនាយសំពៅនោះថា ណ្ហើយចុះ ចូរអ្នកទាំងឡាយមើលមហោស្រពតាមសប្បាយចុះ, កុំគិតព្រួយបារម្ភឡើយ, ចាំខ្ញុំឲ្យរាជ-បុរសទៅថែរក្សាសំពៅឲ្យ ។ ព្រះរាជាទ្រង់ត្រាស់ហៅកុមារទាំងពីរមកបង្គាប់ថា ម្នាលបា, ចូរអ្នកនាំពួកសេវក.ទៅថែរក្សាសំពៅឲ្យពួកអ្នកជំនួញឯស្ទួនផង ។ ឯកុមារទាំងពីរ ក៏ទទួលព្រះរាជឱង្ការនាំពួកសេវកៈទៅថែរក្សាសំពៅ, នាំគ្នាអង្គុយពីរនាក់បងប្អូនក្នុងទីមួយ ។

គ្រានោះ ព្រះនាងកេសិនីទេវី ទ្រង់យល់សុបិននិមិត្តឃើញថា ព្រះរាជានឹងព្រះនាងទេវី ព្រមទាំងព្រះរាជកុមារទាំងពីរព្រះអង្គ ទ្រង់គង់នៅជាមួយគ្នា ក្នុងសាលាវិនិច្ឆ័យ; មានបុរសពីរនាក់ យកផ្កាឈូកស មកជម្រល់លើព្រះហស្តព្រះរាជា ព្រះអង្គទ្រង់ទទួលហើយបាចទៅលើព្រះនាងទេវី ព្រះនាងទ្រង់សៀតលើព្រះកាណ៌ទាំងពីរហើយបរិភោគលំអងផ្កាឈូកនោះ, ស្រាប់តែផ្កានោះជ្រះចុះលើព្រះឧរានៃព្រះនាងទេវីទៅវិញ ។ លុះព្រះនាងតើនឡើង ក៏ទ្រង់ព្រះកន្សែង ហូរទឹកព្រះនេត្រល្ហែង ហើយឡើងគង់ទ្រង់រំពឹងគិតថា ព្រឹកស្អែកនេះ អាត្មាអញមុខជាបានជួបនឹងព្រះស្វាមី ព្រមទាំងកូនទាំងគូរបស់អញ មិនខាន

ឡើយ ៗ តាំងពីព្រះនាងទ្រង់យល់សុបិននិមិត្តឃើញដូច្នោះមក ក៏ពុំអាចទប់ទឹកព្រះនេត្របានឡើយ ៗ លុះដល់វេលាពាក់កណ្ដាលរាត្រីយប់ស្ងាត់ ពួកមនុស្សដេកលក់អស់, ជេយ្យទត្តកុមារក៏លក់ទាំងបង្គុយដោយងងុយ គ្របសង្កត់ខ្លាំង, ជេយ្យសេនកុមារដាស់ព្រះអនុជជារឿយៗ ៗ ឯជេយ្យទត្តកុមាររកឧបាយកុំឲ្យថីនមិទ្ធគ្របសង្កត់ពេក ទើបមានព្រះបន្ទូលនឹងព្រះរៀមថា បពិត្រអ្នកបង, បើបងធ្លាប់ដឹងរឿងព្រេងអ្វី សូមនិយាយប្រាប់ខ្ញុំផង ៗ ជេយ្យសេនកុមារមានព្រះបន្ទូលថា ប្អូនអើយ, បងពុំធ្លាប់ដឹងរឿងព្រេងអ្វីដទៃទេ, បងដឹងតែរឿងដែលយើងព្រាត់ប្រាសគ្នាប៉ុណ្ណោះ ៗ - បពិត្រអ្នកបង, រឿងយើងដែលព្រាត់ប្រាសគ្នានោះដូចម្ដេច? - ម្នាលប្អូន, កាលមាតាបិតារបស់យើងចេញពីព្រះនគរបច្ចិមមកក៏ព្រាត់ប្រាសគ្នា រហូតមកដល់ឥឡូវនេះ ៗ - មាតាបិតារបស់យើងនៅក្នុងកេវដ្ដគ្រាមសព្វថ្ងៃនេះទេតើ, ចុះមាតាបិតាឯណាដែលព្រាត់ប្រាសគ្នា? - មិនមែនដូច្នោះទេប្អូនអើយ, យើងទាំងពីរនាក់មានមាតាបិតាជាមួយគ្នាជាប្រាកដ ៗ - អ្នកបង, បើដូច្នោះសូមប្រាប់ប្អូនផង ៗ - អើប្អូន, ចូរចាំស្ដាប់ចុះ, កាលដែលយើងនៅតូចៗ មាតាបិតារបស់យើងព្រាត់ប្រាសចោលយើងទៅ, ឯមាតាបិតាយើងនោះជាស្ដេចសោយរាជ្យ; ព្រះបិតាយើង មានព្រះអនុជមួយព្រះអង្គ ព្រះនាមអសុកមិត្តជាឧបរាជ ៗ គ្រានោះ អសុកមិត្ត

ឲបកដ  គិតនឹងលើកទ័ពទៅដណ្ដើមកដបម្បត្តិពីព្រះបិតាយើង  ហើយ
ទ្រង់សូកមាសប្រាក់សំពត់ទីងគ្រឿងអលង្ការជាដើម  ដល់ពួកមហាជន
ឲ្យចុះចូលទ្រង់; ពេលនោះបួនជាមានអាមាត្យម្នាក់ជាអ្នកគតញ្ញូ  អាណិត
បិតាយើង  លបរត់ឡើងទៅក្រាបបង្គំទូលតាមរឿងនោះ;  លុះព្រះបិតា
យើង  ទ្រង់ព្រះសណ្ដាប់ពាក្យអាមាត្យនោះហើយ  ក៏ទ្រង់ព្រះចិន្ដាថា
"បើសិនជាអាត្មាអញទីងធ្វើចម្បាំង,  សមជាប្អូនរបស់អញ  ព្រមទាំង
ពួកពលរេហ៍  ទឹងអន្ដរាយខូចខាតច្រើនមិនខាន  បើដូច្នោះ  គួរតែ
អាត្មាអញ  គេចសខ្លួនចេញចាកពដដ្ឋានទៅទាំងកត្រៃថ្ងៃនេះទើបស្រួល";
លុះទ្រង់ព្រះចិន្ដាដូច្នេះហើយ  ក៏ទ្រង់ធ្វើសក្ការៈពប់អានអាមាត្យនោះ
បញ្ជូនឲ្យត្រឡប់ទៅវិញ ។ គពីនោះមកមាតាបិតាយើង  នាំយើង
ទាំងពីរនាក់រត់ចេញពីព្រះនគរមកដល់ស្ទឹងមួយពាក់កណ្ដាលផ្លូវ, ក៏ឈប់
សម្រាកនៅត្រើយស្ទឹងនោះ  បញ្ចុកបាយបង  បំបៅប្អូនឯង  ក្រាល
សំពត់សាដកទ្រាប់ឲ្យប្អូនឯងដេក  ហើយលបក្រោកឡើងសន្សឹម ៗ
ឲបរិតថើបសិរសាបបោសអង្អែលក្បាលបងហើយទៅ ។  កាលបង
កំពុងយំ  ទ្រង់កំសាកមកល្អងលោមបង  ហើយបណ្ដើរគាចុះកងស្ទឹងបាត់
ទៅ ។ កងខណៈនោះ  មានព្រានសំណាញ់ពីរនាក់  បានទាំយើង
យកមកចិញ្ចឹមធ្វើជាកូន ។

ជយ្យទត្តកុមារ ទ្រង់ព្រះសណ្ដាប់រឿងនោះដូច្នោះហើយ ទ្រង់ព្រះកន្សែងថា ឱ! ព្រះជេដ្ឋាបងអើយ, ទំនងជាយ៉ាងហ្នឹងមែនហើយ ។ ជយ្យសេនកុមារ ទ្រង់ឃាត់ព្រះអនុជថា ប្អូនអើយ អ្នកកុំមាត់កឡើយ, បើសិនជាមាតាបិតារបស់យើង មានព្រះជន្មនៅឡើយ មុខជាទ្រង់នឹងតាមមករកយើងមិនខាន ។ – បពិត្រព្រះបង, ចុះនគរយើងឈ្មោះអ្វី?– ឈ្មោះចម្បាកនគរ ប្អូន ។ – ចុះបិតាយើងព្រះនាមដូចម្ដេច? – ម្នាលប្អូន, បងមិនហ៊ានប្រាប់ព្រះនាមព្រះបិតាយើងទេ ។ ឯជយ្យទត្តកុមារ ក៏ខំអង្វរករបងថែ ។ ឲ្យតែប្រាប់ព្រះនាមព្រះបិតា, ត្រាតែជយ្យសេនកុមារអត់ទ្រាំមិនបាន ក៏លើកអញ្ជលីប្រណម្យដោយក្រពុំម្រាមទាំងដប់លើកផ្គង់ឡើងដាក់លើសិរសា ហើយមានព្រះបន្ទូលប្រាប់ព្រះអនុជថា ប្អូនអើយ, ព្រះបិតាយើងព្រះនាមព្រះបាទក្រុងសុភមិត្ត ។ – បពិត្រព្រះជេដ្ឋា, ចុះព្រះមាតាយើងព្រះនាមដូចម្ដេច? – ម្នាលប្អូន ព្រះមាតាយើងព្រះនាម កេសិនីទេវី ។

ចំណែកខាងព្រះនាងកេសិនី កាលបើបានទ្រង់ព្រះសណ្ដាប់ស័ព្ទពាក្យព្រះរាជបុត្រទាំងពីរព្រះអង្គឆ្លើយឆ្លងគ្នាដូច្នោះហើយ ក៏ម្នីម្នាក្រោកឡើងប្រែប្រាលើកព្រះករគគក់ព្រះឧរា ហើយបើកវាំងននស្ទុះរត់ទៅត្រកងព្រះរាជបុត្រទាំងពីរ ហើយទ្រង់ព្រះកន្សែងបម្រះនទៀលនៅទីនោះ ។ កុមារទាំងពីរឃើញហេតុដូច្នោះ ក៏ភ័យតក់ស្លុតយ៉ាងខ្លាំង

ទាំងពីរប្អូនរត់ចេញពីទីនោះទៅ ។ គ្រានោះ ព្រះនាងកេសិនីទេវី ទ្រង់ព្រះកន្សែងសោករកព្រះរាជបុត្រថា

អើយជេយ្យសេន! អើយជេយ្យទត្ត! កូនកំសត់មាសម្ដាយ
អើយ, ម្ដាយហ្នឹងហើយឈ្មោះកេសិនី, ចូរកូនពីរអ្នក
ស្គាល់ចុះ ចូរអ្នកត្រឡប់មកវិញកូនអើយ, ម្ដេចក៏អ្នកឃើញ
ម្ដាយហើយរត់ចោលម្ដាយទៅ ឬមួយអ្នកព្រាត់ប្រាសចាក
ម្ដាយយូរ ហើយភ្លេចម្ដាយទេដឹង? តាំងពីម្ដាយព្រាត់ប្រាស
ចាកអ្នកកាលណា ម្ដាយរែងរងទុក្ខខ្លោចផ្សាឥតស្រាកល្ហែ
ទេ, កន្លងរាប់កាលប៉ុណ្ណោះ ម្ដាយឥតបានសុខបន្តិចបន្តួច
ឡើយ ។

គ្រានោះ កុមារទាំងពីរជ្រាបច្បាស់ថាព្រះមាតារបស់ខ្លួនហើយ ក៏ត្រឡប់មកក្រាបទ្រង់ព្រះកន្សែងសោកទៀបព្រះបាទទាំងពីរ របស់មាតា ។ ពួកអ្នកសំពៅ ឮសូរស័ព្ទកោលាហលដូច្នោះហើយ ក៏ប្រាប់ដំណឹងនោះដល់នាយសំពៅ ។ នាយសំពៅឮដំណឹងនោះហើយក៏ខឹងរន្ធត់រត់ទៅក្រាបបង្គំទូលព្រះរាជាថា សូមព្រះរាជតេជះតម្កល់លើត្បូង, សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ, ដ្បិតរាជបុរសរបស់ព្រះអង្គជាមនុស្សកាចទ្រនង់ទ្រើសឃ្នង ប៉ងនឹងប្រព្រឹត្តមោះពុំគាប់ចំពោះករិយារបស់ទូលព្រះបង្គំជាខ្ញុំ បានទាំងចាប់បង្ខំឲ្យកើតចលាចលទៅក្នុងនាវ ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យនាយសំពៅនោះហើយ ក៏ទ្រង់ក្រោធពិរោធយ៉ាងខ្លាំងហើយទ្រង់ត្រាស់បង្គាប់ពេជ្ឈឃាតថា នែប្រែស្ដេងទាំងឡាយ, ចូរអ្នកទាំងឡាយចាប់កុមារទាំងពីរនេះចង នាំយកមកឲ្យអញកុំត្រាប្រណី ៗ ពេជ្ឈឃាតទាំងនោះ ក៏ទទួលព្រះរាជឱង្ការទៅធ្វើបាបកុមារយ៉ាងខ្លាំងចាប់ចងដោយចំណង៥ប្រការ នាំទៅក្រាបបង្គំថ្វាយព្រះរាជា ៗ ឱម្មុខឲ្យអាសូរ ព្រះរាជកុមារមានព្រះកាយាប្រឡាក់ដោយឈាម ហូរហោមដូចគេលាបល័ក្ខលឿងខ្ចី ៗ ព្រះរាជាទ្រង់ត្រាស់ប្រាប់ពួកពេជ្ឈឃាតថា ចូរអ្នកទាំងឡាយកាត់ក្បាលវា កុំទុកឲ្យនៅ នាំឲ្យអាស្រូវអាប់កេរ្ដិ៍ឈ្មោះ ៗ ពេជ្ឈឃាតក៏នាំយកព្រះរាជកុមារទៅព្រៃស្មសាន ៗ គ្រានោះបុរោហិតម្នាក់ជាអ្នកមានប្រាជ្ញាឃើញហេតុនោះហើយ ក៏គិតថា "ទំនៀមស្ដេចពីបុរាណរៀងមក តែងធ្វើនូវអំពើដែលបានពិចារណារួចហើយ"; កាលគិតដូច្នោះហើយក៏ហៅកុមារទាំងពីរមកសួរថា នែអ្នកទាំងពីរ, អ្នកមានទោសដូចម្ដេច? ៗ ជេយ្យសេនកុមារ ដំរាបបុរោហិតថា ខ្ញុំបាទឥតមានទោសតែអ្វីទេ ៗ បុរោហិតក៏ឃាត់ពួកពេជ្ឈឃាតឲ្យបង្អង់សិន ហើយចូលទៅកាន់ព្រះរាជមន្ទីរយ៉ាងរួសរាន់ដោយខ្លួនឯង, ក្រាបបង្គំទូលសួរព្រះរាជាថា សូមទ្រង់ព្រះមេត្ដាប្រោស, ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យពួកពេជ្ឈឃាតនាំយកកុមារទាំងពីរទៅធ្វើគត់, តើព្រះករុណាបាន

ទស្សនាការទោសដូចម្ដេច? ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ពាក្យបុរោហិតនោះហើយ ទើបទ្រង់ឲ្យបុរោហិតនោះទៅយកកុមារមកវិញ ។ បុរោហិតក៏ចុះពីព្រះរាជមន្ទីរ រត់ទៅនាំកុមារទាំងពីរមកឡើងលើក្រឡាគំនាល់ ។ ព្រះរាជាទ្រង់ត្រាស់សួរកុមារទាំងពីរថា ហេតុអ្វីក៏ឯងធ្វើអំពើអាក្រក់ក្លាហានយ៉ាងនេះ? ។ ជេយ្យសេនកុមារក្រាបបង្គំទូលថា "សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំព្រះអង្គទាំងពីរនាក់ពុំបានធ្វើអំពើអាក្រក់យ៉ាងនេះទេ" ហើយក្រាបបង្គំទូលតាមសេចក្ដីពិតដោយសព្វគ្រប់ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ស្ងួតព្រះរាជហឫទ័យ ទ្រង់ត្រាស់សួរថា ចុះនគរអ្នកឈ្មោះអ្វី? ។ ជេយ្យសេនកុមារក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, នគរទូលព្រះបង្គំជាខ្ញុំឈ្មោះចម្បាកនគរ ។ – ចុះមាតាអ្នកឈ្មោះអ្វី? – ព្រះមាតាទូលព្រះបង្គំជាខ្ញុំព្រះនាមកេសិនីទេវី ។ – ចុះបិតាអ្នកឈ្មោះអ្វី? ។ – សូមទ្រង់ព្រះមេត្តាប្រោស, ព្រះនាមព្រះបិតាទូលព្រះបង្គំជាខ្ញុំពុំហ៊ានក្រាបបង្គំទូលទេ ។ – ម្ដេចក៏អ្នកមិនហ៊ានប្រាប់? ។ – សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំខ្លាច ។ – អ្នកកុំខ្លាចឡើយ, ប្រាប់មកចុះ ។ លំដាប់នោះជេយ្យសេនកុមារ លើកកំបង់អញ្ជលីបែរណាម្យដាក់លើសិរសាក្រាបបង្គំទូលព្រះនាមព្រះបិតាថា បពិត្រព្រះរាជសម្ភារ ព្រះបិតាទូលព្រះបង្គំជាខ្ញុំព្រះនាមព្រះបាទក្រុងសុកមិត្ត ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ហាក់ដូចជានឹងបែកព្រះឧរជា ៧

ភាគ ទ្រង់តក់ស្លុតរន្ធត់ក្នុងព្រះរាជហឫទ័យ ទ្រង់ស្ទុះក្រោកចាកព្រះមន្ទីរ ទៅក្រកន់ឱបព្រះរាជបុត្រទាំងពីរ ទ្រង់ព្រះកន្សែងសោកសន្ទប់បាត់ព្រះស្មារតីក្នុងទីនោះឯង ។ គ្រានោះ ពួករាជបុរសមានអាមាត្យជាដើមក្តី ពួកស្រីស្នំទាំងឡាយមានព្រះនាងទេវីជាប្រមុខក្តី ពួកទាហានទាំងឡាយ មានក្រុមទាហានដំរី ទាហានសេះជាដើមក្តី ក៏សោកសន្ទប់បាត់ស្មារតីក្នុងទីនោះទាំងអស់ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ កាលព្រះសាស្តាទ្រង់ប្រកាសសេចក្តីនោះ ទ្រង់ត្រាស់ថា:

ពួកបណ្តាជន ព្រមទាំងកូននឹងប្រពន្ធក្តី ពួកអាមាត្យមានព្រះរាជាជាដើមក្តី ពួកឈ្មួញក្តី ពួកព្រាហ្មណ៍ក្តី ពួកនាងទេវីក្តី ពួកស្រីស្នំស្រីផ្កាក្តី ពួកទាសាទាសីក្តី ពួកសេនា-ទាហាន មានសេនាដំរីសេនារថនឹងសេនាថ្មើរជើងជាដើមក្តី សឹងនាំគ្នាលើកដៃគក់ទ្រូងទ្រហោយំដួលដេករវើករវាំ ក្នុងព្រះរាជដ្ឋាននៃព្រះបាទក្រុងសុកមិត្ត, ប្រៀបបីដូចដើមរាំងដែលបាក់ដោយខ្យល់ព្យុះ ពុំនោះដូចជាដើមឈើពួរដែររបើតហើយខ្យល់បោកកំទេចដួលទ្រោះ ។

គ្រានោះ ព្រះរាជាទ្រង់មានព្រះអស្សាស: ធូរស្រួលឡើងហើយ ទ្រង់ត្រាស់ព្រះរាជបញ្ជាឲ្យស្រាយចំណងព្រះរាជបុត្រា ព្រះរាជកុមារ

ទាំពីរក៏មានព្រះសរីរៈញ័រដូចគេទាត់ដោយអំណាចមរណភ័យ ៗ ទើបព្រះបក្រីទ្រង់បញ្ឆាក់ព្រះរាជបុត្ររបស់ព្រះអង្គ ដោយពាក្យនេះថា:

ហៃជេយ្យសេន ជេយ្យទត្ត, កូនស្ងួនកំសត់មាសឪពុកអើយ! បិតាហ្នឹងហើយ ឈ្មោះព្រះបាទក្រុងសុកមិត្ត. ចូរអ្នកស្គាល់ចុះ ៗ ម្នាលកូន, ម្តេចក៏អ្នកទទួលកម្មការបរក្រក់ម៉្លេះ? អ្នកនៅក្នុងទីក្រុងនេះយូរយារណាស់ហើយ ម្តេចឡើយក៏អ្នកមិនប្រាប់បិតា ៗ

ព្រះរាជកុមារទាំងពីរ ក្រាបបង្គំទូលស្នងព្រះរាជឱង្ការថា សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំពុំស្គាល់ព្រះអង្គ ព្រោះព្រានសំណាញ់ចាប់យកទូលព្រះបង្គំជាខ្ញុំ ទៅយូរណាស់ហើយ ៗ

លុះព្រះរាជកុមារញុំាងព្រះរាជបិតាឲ្យស្គាល់ជាក់ហើយ ទើបក្រាបចុះទៀបព្រះបាទាព្រះបិតា ទ្រង់ព្រះកន្សែងសោកក្រៀបរាប់អំពីសេចក្តីទុក្ខព្រួយក្នុងការព្រាត់ប្រាសតាំងពីដើមដំបូងសព្វគ្រប់ប្រការ ៗ ទើបព្រះរាជាទ្រង់ត្រាស់សួរថា ហៃបា, ចុះមាតារបស់អ្នកនៅឯណា? ៗ ព្រះរាជកុមារក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ព្រះមាតាគង់នៅក្នុងសំពៅ ៗ ព្រះរាជាទ្រង់សោយព្រះបីតិសោមនស្សស្រស់ស្រាយរីក

ពយ, ទើបព្រះរាជាព្រមទាំងរាជកុមារទាំងពីរ ទ្រង់ចេញចាកព្រះបរម· រាជវាំង ជាមួយនឹងពួកសេវកាមាត្យ សំដៅទៅមាត់ស្ទឹង ឡើងទៅលើសំពៅរបស់ពួកពាណិជ ៗ គ្រានោះ ព្រះនាងទេវីគង់នៅកណ្ដាលសំពៅ បានទស្សនាការឃើញព្រះរាជាព្រមទាំងព្រះរាជបុត្រ ជ្រាបជាក់ជាព្រះរាជស្វាមីហើយ ក៏ទ្រង់ព្រះកន្សែងសោកសន្ទប់បាត់ស្មារតី ៗ ព្រះរាជាក៏មានព្រះសរីរៈញាប់ញ័រ ទ្រង់ព្រះកន្សែងសោកសន្ទប់បាត់ព្រះស្មារតីក្នុងទីនោះដែរ លុះទ្រង់មានព្រះអស្សាស.ធូរស្រាលឡើង ក៏ទ្រង់លើកព្រះសិរព្រះនាងទេវីដាក់លើព្រះឧរូព្រះអង្គ ហើយទ្រង់ព្រះកន្សែងសោកទៀត ៗ ព្រះរាជកុមារទាំងពីរ ក៏លើកព្រះករប្រណម្យឡើងដាក់លើព្រះសិរសា ទ្រង់ព្រះកន្សែងសោកទៀត ៗ លំដាប់នោះព្រះរាជាទ្រង់ព្រះកិលាបហើយត្រាស់ថា:

> ម្នាលកេសិនីមាសបង, ចូរនាងក្រោកឡើង ស្វាមីមកដល់ទីនេះហើយ, កូនទាំងគូរបស់នាងក៏មកដែរ, នាងក្សារឡើងហើយឬ? ៗ

លំដាប់នោះព្រះនាងទេវី ទ្រង់ក្សារស្មារតីឡើង ក៏ស្ទុះទៅក្រាបទៀបព្រះបាទនៃព្រះរាជា ហើយត្រាស់ព្រះរាជសវនីយថា:

និព្វុតោ ទានិ មេ សោកោ និព្វុតំ ទានិ មេ ភយំ
និព្វុតោ វិបលោ សោកោ បស្សន្តា ឦទិសំ បតិ

ឥឡូវនេះសេចក្ដីសោករបស់ខ្ញុំម្ចាស់រលត់ហើយ, ឥឡូវនេះ ភ័យរបស់ខ្ញុំម្ចាស់រលត់ហើយ, សេចក្ដីសោករើរាយរលត់ ហើយ ព្រោះបានជួបនឹងព្រះរាជស្វាមី ។

រួចព្រះនាងទេវី ស្ទុះទៅក្រសោបឱបព្រះរាជបុត្រទាំងពីរ សោកសន្ទប់បាត់ព្រះស្មារតីក្នុងទីនោះទៀត ។ គ្រានោះពួកអាមាត្យទាំងអស់នឹងពួកស្រីស្នំហេននាងទេវីជាប្រធាន ឃើញក្សត្រទាំងនោះដូច្នោះ ហើយ ក៏សោកសន្ទប់បាត់ស្មារតីជាមួយគ្នាក្នុងទីនោះឯង ។ ក្សត្រទាំងនោះសោយសោកកែររពេញទាំងថ្ងៃសំពៅ ដរាបដល់ទិនករអស្តង្គត, ពួកអាមាត្យក៏រត់ទៅនាំយកព្រះសុពណ្ណសិវិកា រំលេចដោយកែវទាំង ៧ ប្រការមកហែយកព្រះរាជា នឹងព្រះនាងទេវី ព្រមទាំងព្រះរាជបុត្រទាំងពីរ ត្រឡប់ទៅកាន់ព្រះរាជមន្ទីរវិញ ។

គ្រានោះព្រះរាជាទ្រង់ឲ្យរៀបពិធីលេងមហោស្រពអស់ ៧ ថ្ងៃ ទើបក្សត្រថ្វៃទ្រង់អភិសេកព្រះនាងទេវីជាអគ្គមហេសី, ទ្រង់ប្រទាននាទីឧបរាជដល់ជេយ្យសេនកុមារ; ប្រទានដំណែងសេនាបតីដល់ជេយ្យទត្តកុមារ ។ តាំងពីនោះមក ព្រះអង្គទ្រង់ធ្វើបុណ្យទាំងឡាយ មានឲ្យទានជាដើមដរាបដល់ទីបំផុតព្រះជន្មាយុ ទ្រង់ព្រះទិវង្គតទៅយកព្រះជាតិក្នុងពិភពតុសិត ។

ព្រះសាស្ដាទ្រង់នាំធម៌ទេសនានេះមកសំដែងប្រាប់ហើយ ទ្រង់សមោធានជាតកត្រាស់ព្រះគាថាចុងបំផុតនេះថា:

អសុភមិត្តោ ទេវទត្តោ អានន្ទោ ជេយ្យទត្តោ អហុ
រាហុលោ ជេយ្យសេនោ ច កេសិនី ទេវី សុន្ទរា
មាតា អាសិ មហាមាយា បិតា សុទ្ធោទនោ អហុ
សុភមិត្តោ លោកនាថោ ឯវំ ធារេថ ជាតកំ

*អសុភមិត្ត បែរវិលវិលមកបានជាទេវទត្ត; ជេយ្យទត្តកុមារ បែរវិលវិលមកបានជាអានន្ទ; ជេយ្យសេនកុមារ បែរវិលវិលមកបានជារាហុល; នាងកេសិនីទេវី បែរវិលវិលមកបានជានាងយសោធរា; ព្រះមាតាបែរវិលវិលមកបានជាព្រះនាងមហាមាយា; ព្រះបិតាបែរវិលវិលមកបានជាព្រះបាទសុទ្ធោទន; ព្រះបាទក្រុងសុភមិត្ត គឺតថាគតជាបរមលោកនាថសាស្តាចារ្យហ្នឹងឯង; អ្នកទាំងឡាយ ចូរចងចាំជាតកដែលតថាគតសំដែងមកយ៉ាងនេះចុះ ។*

ចប់សុភមិត្តជាតក ទី ៩ តែប៉ុណ្ណោះ

# រឿងសៅរ៍សោយ

(សិរោរជាតក)

ព្រះមហាឧត្តមវិជ្ជា ផលញ្ញាណោ បឹង-ប៉ម

អាចារ្យសាលាបាលីរងវត្តបទុមវតី ក្រុងភ្នំពេញ

រៀបរៀងតាមតម្រាយសាស្ត្រាស្លឹករឹត

(តមក)

---

ប៉ោលគោកយំលន្ទោច　លលកខ្មោចទំដើមពាំង
ខ្ទិងស្រាកស្រែកឮខ្លាំង　គូកកូពាំងស្រែកបន្ទប់ ៗ
មៀមមុមទំដើមត្រាច　យំគួរខ្លាចព្រឺស្ងែងស្ងប់
ទីទុយទំដោយម្ងប់　ឈើប្រសព្វមែកត្រៃឈ ៗ
ទុកទ្រូហ៊ូពួយំ　ស្ទូរណ្ដំទំមែកជ្រៃ
បបាតទ្ទូរប្រឡៃ　មានមាន់ព្រៃទំក្ដាំងផា ៗ
អស់សត្វផងទាំងឡាយ　ហើរប្រញាយដោយហ្វូងវា
ចុះទំយំរកគ្នា　លោតស្ទុះស្ទាបុងចំបុ ៗ
ខ្លះហើររកផលា　ចឹកភោក្ដាជាចំណី
តិចហើយហើរទៅខ្ទី　ទំចំបុចម្ប៉ាពេញ ៗ
ត្រសេះហើរត្រសង　ទំដើមក្ទូងហើយហើរចេញ
ទៅទំដើមរំដេញ　ខ្លះហើរចេញទំរំដួល ៗ
តាវ៉ើសំឡេងខ្សោក　សត្វប៉ោលគោកសំឡេងស្រួល

ហើរទៅទំដើមស្នួល ផុះលើទួលទីព្រៃធំ ។
ស្ដេចស្ដាប់សត្វមាត់សត្វ ស្ងួនស្រងាត់ជិតជើងភ្នំ
ក្នុងទ្រូងណែនអួលក្រំ ស្ដេចខះខំបរអាជានេយ្យ ។
វង្វេងពុំដឹងសោះ ទឹងបំពោះទៅទីទៃ
លេចវាលហើយចូលព្រៃ លំបាកក្រៃអង្គអាត្មា ។
ស្ដេចត្រាច់ក្នុងព្រឹក្សព្រៃ លំបាកក្រៃឥតឧបមា
ពុំមានភោជនា គ្រាន់ភោគ្គាប់អែតផ្ទៃ ។
ទូរទូរាអង្គ ក្សត្រវរវង្សគង់អាជានេយ្យ
តត្រកុកក្នុងព្រៃ ទើបទម្ងុះដល់វាលស្រែ ។
ស្ដេចឈ្វៀងព្រះនេត្រទៅ យល់ស្រូវនៅនោះឯងឯង
ស្ដេចគង់ហើយគិតថៃ នេះស្រុកគេមិនទេឡើយ ។
ប្ដោះគួរអញសំដៅ សព្វារទៅស្រុកនោះហើយ
រកបាយគេទៅរើយ ក្រែងគេឲ្យអញតិចវ៉ា ។
ស្ដេចគិតដូច្នោះហើយ ពុំលង់ឡើយព្រះកាជា
ស្ដេចបរអស្សពាហន៍ ឆ្ពោះទៅនាស្រុកនោះខ្ញី ។

បទភុជង្គលីលា

ទឹងថ្ងៃសំដែងស្រដី អ្នកស្រុកប្រុសស្រី តែងធ្វើស្រែស្រូវ ។
ថ្ងៃនោះមានប្រុសមួយគូ ជាម្ចាស់ស្រែស្រូវ គន់គិតជូនថៃ ។

រៀបចំទីផទៅតាំងស្រែ ក្សិណនោះឯងឯង យកស្ទឹកដោះបាយ ។
ដោះស្រេបយកត្រីងៀតលាយ ហើយខ្ចប់ទាំងបាយ ដាក់ល្អីយកទៅ ។
លុះដល់វាលស្រែឯក្រៅ ចួនពេលនោះនៅ ពុំទាន់ឃ្លានបាយ ។
ទើបទុកល្អីបាយនៅអាយ ហើយដើរទៅនាយ មើលស្រូវសាលី ។
បង្អើលបក្សាបក្សី ជូនថៃឃ្មាតខ្មី ឥតបីបណ្ដោយ ។
កាលនោះមានឆ្កែកំព្រយ មួយដើរតាមក្រោយ ដល់ទីនោះខ្មី ។
ឃើញកញ្ចប់បាយក្នុងល្អី ទើបពាំរត់បី ពីទីនោះទៅ ។
កាលនោះព្រះបាទសិសៅរ៍ ស្ដេចបរសេះទៅ តាមផ្លូវក្បែរស្រែ ។
គ្រានោះរីឯម្ចាស់ស្រែ មើលស្រូវជូនថៃ ស្រេចហើយវិលខ្មី ។
ទៅរកកញ្ចប់ក្នុងល្អី ពុំឃើញចំណី រកអ្វីស៊ីគ្មាន ។
ខឹងណាស់ដោយសារវាឃ្លាន ហើយគន់គិតស្មាន ថាមានមនុស្សយក ។
កាលនោះពង្សព្រុទ្ធពន្ធក ស្ដេចបរសេះមក ដល់ស្រែនោះណា ។
ម្ចាស់ស្រែនោះបែរនៃគ្រា យល់ព្រះពជា ពាក់មកុដពិសី ។
ឃើញជាកញ្ចប់បាយខ្មី លោស្ទុះទៅបី ដល់ពោធិសត្វ ។
ស្រែកដេររួចតែពីមាត់ ថា "អាខូចក្ដាត់ ចិត្តពោរអប្រិយ ។
មឹងមកពីទីណាវ៉ី ហ៊ានលួចបាយត្រី ពីល្អីអញអស់ ។
អញទុកអំមិញស្រស់ៗ លួចយកស៊ីអស់ ត្រីងៀតមួយដុំ ។
បើឃ្លានម្ដេចមឹងមិនសុំ មឹងឯងនេះពុំ រួចពីអញវ៉ាយ ។

ស៊ីហើយមិនធ្វើពាយឆាយ   យកកញ្ចប់បាយ   ទូលលេងជាល្បែង" ។
ក្រៀណនោះពោធិសត្វថ្លែង   ប្រាប់ថា "អញឯង   មិនជាអ្នកលួច ។
ម្តេចឡើយអ្នកហ៊ានកាន់កួច   ថាអញនេះលួច   សំណុំបាយឯង ។
ដែលពាក់លើក្បាលចិញ្ចែង   មកុដអញជាក់ស្តែង   ម្តេចឯងមាក់ងាយ ។
ថាអញលួចសំណុំបាយ   ហើយគិតចង់វាយ   អញឯងដូច្នោះ" ។
រីឯម្ចាស់ស្រែស្រូវនោះ   យល់ស្តេចឆ្លើយដោះ   ដូច្នោះវិញណា ។
ម៉្លោះហើយរឹងរឹតក្រោធា   ខឹងក្នុងចិត្តា   រឹងជាដេរទៀត ។
ថា "អាកំសត់ពាលម្សៀត   មាត់រឹងហ៊ានធ្មៀត   ដដែកប្រកែក ។
តិចលោអញចាប់មាត់ហែក   ម្តេចមិនប្រកែក   អញស្គាល់ចំហុត ។
ម្តេចមិនហ៊ានរឹងថាមកុដ   កញ្ចប់ស្អុយ ៗ   មកថាមកុដអា ។
មុខឯងមានមកុដពីណា   ម្តេចហ៊ានមុសា   ពុំខ្លាសគេឯង ។
អានេះចិត្តកាចឥតក្រែង   អញវាយអំបែង   ក្បាលឯងជាមួន" ។
ថាហ្នោះស្ទុះចាប់បានដង —   ដនួញមកហោង   វាក់មាត់ក្សត្រា ។
វាយដំធាក់ច្រាជ៉ា   ពុំមានមេត្តា   ករុណាមហាក្សត្រ ។
ឈាមប្រាលរឡាលច្រើនក្តាត់   ព្រះពោធិសត្វ   កើតមានវេទនា ។
ពុរពង់អស់ទាំងកាយា   ជាំជាំមហិមា   មានវេទនាណាស់ ។
អង្វរលើកដៃសំពះ   "ឱះ ឱ! លោកម្ចាស់   លែងជីវិតខ្ញុំ ។
ព្រះមកុដកែវរតនទាំងដុំ   នេះរបស់ខ្ញុំ   ពិតពុំមុសា ។

ឥឡូវអ្នកឃើញថាជា កញ្ចប់គោជនា ប្រាកដមែនពិត ៗ
ខ្ញុំសូមសៅតែជីវិត របស់អ្នកពិត អ្នកយកចុះណ៎" ៗ
អ្នកនោះឮព្រះព៍តា ថាឲ្យប្រោះណា បន្ទោចឹងបាត់ ៗ
ទើបយកព្រះមកុដកែវរ័តន៍ លែងពោធិសត្វ ហើយបណ្តេញថា ៗ
"អាះទៅឲ្យឆាប់ៗណ៎" ពីនេះទៅណា កុំមកឡើយនែ ៗ
បើមកក្រោយនោះនឹងក្ស័យ ជីវិតប្រល័យ បាត់បង់ពុំជា" ៗ
កាលនោះសម្តេចក្សត្រា ស្តេចបរអេស្យពាហន៍ ពីទីនោះទៅ ៗ
ទ្រង់មានព្រះកាយហ្មងសៅ ពកជុំជាំខ្មៅ លំបាកពេកពន់ ៗ
ត្រាំត្រាទូកទូរន់ ស្ទើរក្ស័យព្រះជន្ម ក្នុងព្រៃស្មសាន ៗ
ឈាមហូរជោកជាំអង្គប្រាណ ទុក្ខពន់ប្រមាណ ទើបសោយសោកថា ៗ
"ឱះ ឱ ! ខ្លួនអញនេះណា មករងទុក្ខា ខ្លាំងក្លាស្ទើរក្ស័យ ៗ
ទាំងនេះព្រោះអញនេះនៃ មានៈខ្លាំងក្រៃ ពុំជឿហោរា ៗ
ដែលគេទាយឲ្យអាត្មា ទើបរងទុក្ខា វេទនាទាំងម៉្លេះ" ៗ
ទ្រង់សោកហើយទ្រង់ដឹកសេះ បណ្តើរគេចវេះ អំពីទីនោះ ៗ
ដល់ស្រែឯមុខចំពោះ រីម្ចាស់ស្រែនោះ ជាមនុស្សខ្ជិលខ្ជា ៗ
កំជិលពុំដែលយាត្រា មើលស្រូវឡើយណា ពោលជាយូរថ្ងៃ ៗ
ទើបជាបន្ទោះល្អក្រៃ ឲ្យចោរចង្រៃ លួចប្រូតស្រូវនោះ ៗ
ហើយពរែកយកទៅស្នោះ រីឯក្រោយនោះ ម្ចាស់ស្រូវនោះឯង ៗ

ចេញទៅពីផ្ទះសម្បែង  លីតាំងលំពែង  ដើរដល់ស្រែស្រូវ ។
ក្រឡេកមើលស្រែនោះកូវ  យង់យល់ឯស្រូវ  រលីងទៅខ្ទះ ។
ម្ចាស់ស្រូវនោះកូវខឹងណាស់  ទើបប្រែប្រាណប្រះ  ទៅតូនកូនស្រូវ ។
គយគន់លបមើលគ្រប់ផ្លូវ  ក្រែងចោរនោះកូវ  មកលួចទៀតណា ។
ថ្ងៃនោះជាគ្រោះមហិមា  ចួនជាក្សត្រា  ព្រះបាទសិរសោរ៍ ។
ស្តេចព្រះទីនាំងទៅ  តាមផ្លូវដែលនៅ  ជិតស្រែនោះនៃ ។
ម្ចាស់ស្រែឆាកបែររំពៃ  យល់មហាក្សត្រថ្ងៃ  បរសេះទៅជិត ។
ម្ចាស់ស្រូវមានសញ្ញាគិត  ថាជាចោរពិត  លោលើកលំពែង ។
ស្រែកដេរគំរាមកំហែង  ឥតខ្លាចឥតក្រែង  ដល់តិចឡើយនៃ ។
ថា "អាចិត្តចោរចង្រៃ  លួចស្រូវសព្វថ្ងៃ  មិនដែលប្រទះ ។
ឥឡូវនេះទើបពើបពះ  ខ្លួនមឹងឯងច្បាស់  ជាចោរលួចស្រូវ" ។
ទើបស្តេចឆ្លើយថា "ពុំត្រូវ  ខ្ញុំឯងនេះកូវ  មិនជាចោរលួច ។
ម្តេចឡើយអ្នកហ៊ានកាន់កួច  ខ្ញុំនេះឥតលួច  កុំដេរឡើយណា" ។
បុរសនោះមើលឃើញថា  ព្រះខាន់នៅនា  ហត្ថាមហាក្សត្រ ។
ជាក់ជាកណ្តៀវពេកក្តាត់  ម្ល៉ោះហើយទើបគាត់  រឹងជាក្រោធក្រៃ ។
ថា "នែអាចោរចង្រៃ  កណ្តៀវនៅដៃ  ម្តេចហ៊ានប្រកែក ។
អញវាយក្បាលមឹងឲ្យបែក  ម្តេចមិនដាដែក  ប្រកែកមកផង" ។
ថាហើយក៏ចាប់យកដង  លំពែងសំពង  ពង្សពោធិសត្វ ។

បែកឈាមហាមជ្រែនក្តាត់ ស្រក់ស្រោចមុខមាត់ ទន់តាំងកាយា ៗ
ព្រះអង្គទ្រង់ព្រះចិន្តា គន់គិតអទិប្បា សង្វេគពេកក្រៃ ៗ
ថា "ឱ! ព្រះខាន់កែវថៃ កាន់មកសព្វថ្ងៃ ឥឡូវនេះគួរ ៗ
ការប្រែជាកណ្ដៀវស្រូវ គឺកម្មអញគួរ ទើបជាហោះណា" ៗ
ស្ដេចមានព្រះបន្ទូលថា "អ្នកអើយមេត្តា លែងកយខ្ញុំទៅ ៗ
ថាបើកណ្ដៀវពិតនៅ សូមអ្នកយកទៅ ខ្ញុំសូមតែរស់ ៗ
ផងអ្នកខ្ញុំឲ្យទាំងអស់ ខ្ញុំសូមតែរស់ ជីវិតតទៅ" ៗ
បុរសព្រួញហោះអន់ក្ដៅ ពុំសូវមួមៅ បន្ទោរចឹងបាត់ ៗ
ទើបយកព្រះខាន់កែវរ័ត្ន លែងពោធិសត្វ ហើយបណ្ដេញថា ៗ
"មឹងទៅឲ្យឆាប់ៗព៉ កុំមកទៀតណា លួចស្រូវអញនៃ ៗ
បើលួចឯក្រោយទឹងក្ស័យ ជីវិតប្រល័យ សោះសូន្យមរណា" ៗ
ព្រះបាទសិរីសៅរ៍ភជា ស្ដេចទ្រង់វេទនា សល់សែនឥតបី ៗ
ខំអត់សង្កត់ខន្តី ទឹងពាក្យសំដី ដែលគេផ្ដាសា ៗ
ទឹកនេត្រហូរធ្លាក់មកណា ស្រោចស្រប់កគ្រា គួរសង្វេគក្រៃ ៗ
ហើយស្ដេចដើរយាត្រានាយ្យ រកសាវៃ ចេញពីទីនោះ ៗ
ដល់ស្រែឯមុខចំពោះ មានម្ចាស់នៅនោះ រក្សាស្រូវហោង ៗ
ម្ចាស់ស្រូវត្រវឃ្វាលគោផង ដឹកគោទៅចង ឲ្យក៏ស៊ីស្មៅ ៗ
ចងស្រេចពុំបានចាំនៅ ប្រញាប់វិលទៅ បរិភោគា ៗ

(មានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាងវៃឆ្លាសបើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

## កណ្ឌទី ២០

តាំងពីឡៀពីសុំសំបុត្រគេហៀនផ្ញើទៅសុំកងទ័ពអ៊ួនសៀវជាជន្លងឲ្យលើកមកជួយ រហូតដល់ស៊ុនហ៊ីវនិយាយគ្នា នឹងប្រើខុងយ៉ុងឲ្យចេញទៅនិយាយបញ្ចុះបញ្ចូលឡៀពៀវ ។

---

ឡៀពីថា គ្រានេះអ៊ួនសុតស្លាប់ក៏ព្រោះយើងលើកកងទ័ពទៅច្បាំង ដែលនឹងឲ្យមានសំបុត្រទៅសុំកងទ័ពអ៊ួនសៀវនោះ ប្រាកដជាអ៊ួនសៀវមិនលើកទ័ពមកជួយទេ ព្រោះមិនមានផ្លូវមេត្រីទៅវិញទៅមកនឹងយើង ។

កាន់គេងឆ្លើយថា គេហៀនដែលនៅក្នុងស្រុកពបីជីវនេះ ជាជន្លងនឹងអ៊ួនសៀវ ហើយក៏ត្រូវអធ្យាស្រ័យគ្នានឹងលោកមកពីដើម ខ្ញុំ

បានយល់ឃើញថា ថៅលោកទៅគំនាប់គេហៀនរឿយៗហើយ ថៅលោកទឹងសុំសំបុត្រគេហៀនទៅឲ្យអ្នកសៀវ មុខជាអ្នកសៀវនឹងលើកមកជួយលោកតាមសំបុត្រអ្នកសៀវជាប្រាកដ ៗ ឡេវពីបានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរទើបនិយាយថា "គេហៀននោះជាគ្រូប្រដៅអក្សរយើងមកពីដើម កាលគ្រាយើងនៅក្នុងស្រុកទុនគួន ក្រោយពីនោះមកគេហៀនចូលទៅធ្វើរាជការជានាហ្មឺន ក្នុងរាជ្យព្រះចៅហៀនតេលុះឲ្យ ១០ នាក់ប្រព្រឹត្តទុច្ចរិតអាក្រក់ក្នុងផែនដី គេហៀនក៏លាចេញពីរាជការមកនៅក្នុងស្រុកឈីជីវនេះ" ថាហើយឡេវពីក៏ចាត់ចែងរបស់ទ្រព្យ ហើយនាំខ្លួនគាន់គេងទៅរកគេហៀនឯផ្ទះ ៗ ឡេវពីគំនាប់គេហៀនហើយពណ៌នាសេចក្តីឲ្យគេហៀនស្តាប់គ្រប់ប្រការថា ឥឡូវនេះខ្ញុំមានសេចក្តីទុក្ខព្រួយពន់ពេកណាស់ សំឡឹងមើលទៅឃើញតែលោក, សូមលោកអាណិតខ្ញុំសុំធ្វើជាសំបុត្ររបស់លោក ទៅសុំកងទ័ពអ្នកសៀវឲ្យលើកមកជួយដើម្បីច្បាំងនឹងបួច្ចុ ៗ

គ្រានោះគេហៀនបានស្តាប់ឡេវពីនិយាយ ក៏មានចិត្តអាណិតមេត្តាបានសរសេរសំបុត្រតាមពាក្យឡេវពី លុះធ្វើរួចក៏ប្រគល់ឲ្យឡេវពីៗទទួលហើយក៏លាគេហៀនត្រឡប់ទៅផ្ទះវិញ ហើយប្រើស៊ុនខៀនឲ្យកាន់សំបុត្រនោះទៅឲ្យអ្នកសៀវឯស្រុកគីជីវ ៗ អ្នកសៀវឃើញសំបុត្រគេហៀនដូច្នោះ ក៏គិតតែក្នុងចិត្តថា "ឡេវពីប្រទូសរ៉ាយនឹងអ្នកសុតជា

ប្អូនអញ ៗ ក៏កំពុងគិតនឹងសងសឹកទៀតពី ឥឡូវបើអញមិនលើកទ័ពទៅជួយទេ ក៏បារម្ភចិត្តតេហៀនដែលបានធ្វើសំបុត្រមកដល់ហើយ ” គិតហើយក៏ឲ្យហៅទីប្រឹក្សាមកពីគ្រោះថា គ្រានេះប្អូនមានកំឡាំងជាច្រើនណាស់ ហើយធ្វើអាក្រក់ទឹងព្រះចៅហៀនតេ យើងនឹងលើកទ័ពទៅកំចាត់ប្អូន តើអ្នកទាំងពួងនឹងយល់ឃើញដូចម្តេច ? ។

តៀនហានទីប្រឹក្សាឆ្លើយថា លោកបានលើកកងទ័ពទៅធ្វើសង្គ្រាមគ្រប់ឆ្នាំមិនដាច់ ណាមួយសេនាទាហានកំពុងនឿយហត់ពេកណាស់ ប្រការ ១ ទៀត ស្បៀងអាហារនៅក្នុងជ្រុកសោតក៏ស្តួចស្តើង នៅមិនទាន់ប្រមូលទុកឲ្យគ្រប់គ្រាន់បរិបូណ៌ ដែលលោកនឹងលើកទៅគ្រានេះខ្ញុំបាទឃើញថា ទាហានទាំងពួងនឹងបានសេចក្តីអត់ឃ្លានខ្លាំងណាស់ សុំឲ្យលោកមានសំបុត្រចូលទៅក្រាបទូលស្នើព្រះចៅហៀនតេ ឲ្យទ្រង់ត្រាស់ហាមឃាត់ប្អូន កុំឲ្យលើកកងទ័ពទៅធ្វើអន្តរាយដល់អាណាខេត្តទាំង ពួងឲ្យអាណាប្រជានុរាស្ត្របានសេចក្តីក្តៅក្រហាយ បើប្អូនមិនធ្វើតាមព្រះតម្រាស់ យើងនឹងលើកកងទ័ពធំទៅវាយឲ្យគ្រប់មណ្ឌលខេត្តទាំងពួង ហើយកៀរប្រមូលយកមនុស្សនឹងស្រូវអង្ករបំណីអាហារ រៀបគ្រឿងសស្ត្រាវុធបន្ទុករទេះនឹងទូកបម្រុងទុកឲ្យព្រមយ៉ាងច្រើន ហើយធ្វើសំបុត្រចេញប្រកាសដល់នាហ្មឺនមុខមន្ត្រីក្នុងក្រុងថា ប្អូនជាសត្រូវពដសម្បត្តិ បើនាហ្មឺនទាំងឡាយយល់ឃើញផងយើងក៏បានការ ត្រូវធ្វើដូច្នេះតំរប់ពាឆ្នាំ គង់នឹងសម្រេចការបានដោយងាយ ។

សមផ្ទួយបានព្រះគៀនហង់និយាយដូច្នោះក៏ឆ្លើយថា អ្នកគិតដូច្នេះមិនត្រូវសោះ ព្រោះទាហានរបស់ទៅហ្វាយយើងគ្រានេះ សុទ្ធតែមានថ្វីដៃច្រើនណាស់ បើនឹងគិតកំចាត់ចូចូនោះងាយណាស់ ទុបមាដូចជាលើកដៃផ្កាប់ចុះ ហេតុម្តេចបានជាអ្នកគិតឲ្យយឺតវែងទៅដូច្នេះ? ។ ឈីស៊ីវបានស្តាប់សមផ្ទួយថាដូច្នោះ ក៏ដកពបទៅអ្នួនសៀវថា ធម្មតាសង្គ្រាមមិនមែននឹងមានជ័យជំនះព្រោះទាហានច្រើននឹងតិចនោះទេ វមែងចាញ់ឈ្នះព្រោះទុបាយកលប្រាជ្ញារិះគិតការទៅផ្សេង ។ ឯចូចូនោះទោះពីមានសេនាទាហានតិចជាងយើងក្តីណា តែថាគេមានសតិបញ្ញាជំនាញស្ទាញស្ទាត់ ក្នុងការសង្គ្រាមជ្រៅទូលាយណាស់ ទាំងទីប្រឹក្សាក៏ឆ្លៀវឆ្លាត ដែលនឹងធ្វើបានដោយងាយ ដូចជាកង៏ស៊ុនតានមិនមែនទេ សុំឲ្យលោកធ្វើតាមពាក្យគៀនហង់វិញទើបសម្រេច ។

គួគៅឆ្លើយដំពបអ្នួនសៀវថា គ្រានេះបានកលការល្មមធ្វើហើយ ដែលនឹងរង់បង្អង់ទុកតាមពាក្យគៀនហង់នឹងឈីស៊ីវនោះ មុខជាចូចូនឹងមានគំនិតច្រើនឡើងទៅខាងមុខ ទាហានរបស់យើងនឹងមានសេចក្តីលំបាក ម្យ៉ាងទៀត គេហៀនក៏មានសំបុត្រមកដល់លោកផង បើលោកនឹងមិនលើកទ័ពទៅគ្រានេះ គេហៀននឹងមានសេចក្តីតូចចិត្ត, ប្រការ ១ ឡៅពីក៏ជាពូជព្រះពង្សវង្សទាំងមានចិត្តសត្យទៀងត្រង់នឹងផែនដី គួរហើយលោកនឹងលើកទ័ពទៅជួយឡៅពីធ្វើការកំចាត់ចូចូ

ចេញ ដើម្បីឲ្យព្រះមហាក្សត្រនឹងនាហ៊ឺនមុខមន្ត្រីនៅអាណាប្រជានុកស្រ្តបានសេចក្តីសុខក្សេមក្សាន្តព្រោះគំនិតរបស់លោក ។

អ្នកសៀវបានស្តាប់ទីប្រឹក្សា ៤ នាក់និយាយមិនចុះសុះគ្នា ក៏នៅស្ងៀម ទទួលឃើញខៅហ៊ុវនឹងស៊ុនខាមចូលមក អ្នកសៀវក៏គិតក្នុងចិត្តថា “ខៅហ៊ុវនឹងស៊ុនខាមនេះជាមនុស្សមានសតិបញ្ញាជាងអ្នកទាំងពួង យើងនឹងប្រឹក្សាល្បងមើលគំនិតអ្នកទាំង ២ នេះ តើនឹងគិតឃើញដូចម្តេចវិញ” អ្នកសៀវក៏និយាយប្រាប់ខៅហ៊ុវនឹងស៊ុនខាមតាមដំណើរ ហើយសួរថា អ្នកនឹងឃើញដូចម្តេច? ។

ខៅហ៊ុវនឹងស៊ុនខាមឆ្លើយថា គ្រានេះ ទាហានរបស់លោកក៏មានច្រើនណាស់ ទាំងថ្វីដៃក៏ខ្លាំងពូកែ គួរតែទៅជួយឡៅពីជាពូជព្រះរាជវង្សដែលមានកំលាំងតិច ដើម្បីនឹងកំចាត់ចូចូដែលជាសត្រូវរាជសម្បត្តិចេញ ដូចជាលោកជួយទំនុកបំរុងផែនដី សេចក្តីគាប់ប្រសើរក៏នឹងមានដល់លោកទៅខាងមុខ ។ អ្នកសៀវបានស្តាប់ដូច្នោះក៏ឆ្លើយថា “គំនិតអ្នកទាំង ២ នេះ ត្រូវនឹងចិត្តយើងគិតទុកជាស្រេច” ថាហើយក៏តែងសំបុត្រឲ្យស៊ុនខៀនកាន់ត្រឡប់ទៅឲ្យគេហៀន សេចក្តីថា “យើងនឹងលើកកងទ័ពទៅកំចាត់ចូចូ ឲ្យឡៅពីទៅប្រសព្វគ្នានឹងទ័ពរបស់យើងចុះ” ។ ស៊ុនខៀនទទួលយកសំបុត្រនោះ ហើយក៏លាអ្នកសៀវត្រឡប់ទៅ លុះដល់ស្រុកឈីជីវក៏យកសំបុត្រនោះទៅជូនឡៅពី ។

ឯអ្នកសៀវគឺតាំងតែគេណ្ណាទាហាន ឲ្យឆ៉ាន់លៀង, ប៊ុនធីវ លើកទាហានចេញទៅជាទ័ពមុខ ឲ្យស៊ុមជួយទឹងអងគីជាបាឡាត់ទ័ពបង្គាប់ទាហានតូចធំទាំងពួង ខ្លួនអ្នកសៀវជាមេទ័ពធំលើកទាហានជិះសេះ ១៥ ម៉ឺន, បញ្ចូលគ្នាជាទាហាន ៣០ ម៉ឺនឲ្យទៀនហង, ទៅហ៊ីវ, ស៊ុនខាម, ៣ នាក់នេះជាទីប្រឹក្សា លុះត្រៀមទាហានបានស្រេចវេលាណា ដល់ឫក្សល្អក៏លើកទ័ពចេញទៅ ។ គួតៅជំរាបអ្នកសៀវថា ដែលលោកទឹងលើកកងទ័ពទៅក៏បាត់ចូឆូនោះ ចូរធ្វើការកាន់យកអាណាខែត្រទាំងពួង ទឹងបណ្តាក់ស្តុកុំឲ្យគេបត្រឡប់ចូលទៅខាងចូឆូបាន ។

អ្នកសៀវសួរថា អ្នកទឹងឲ្យធ្វើយ៉ាងម្ដេច ? ។ គួតៅជំរាបថា កាលបើលោកទឹងលើកកងទ័ពចេញទៅនោះ សុំឲ្យតែងសំបុត្រទៅបិទទុកគ្រប់ទ្វារស្រុក ក្នុងអាណាខែត្រនីមួយៗ ពោលទោសចូឆូថា ចូឆូធ្វើការអាក្រក់ប្រព្រឹត្តទុច្ចរិតជាក្បត់សត្រូវទឹងផែនដី ។

អ្នកសៀវបានស្ដាប់ដូច្នោះ ក៏មានសេចក្ដីត្រេកអរពន់ពេក ទើបនិយាយនឹងតាន់លឹមដែលជាអាល័ក្សពីគ្រាព្រះចៅហាន់តេ ជាព្រះអយ្យកោព្រះចៅហៀនតេ កាលតាំងតុះលើកចូលមកនៅក្នុងស្រុកឡុកអៀងនោះ តាន់លឹមវេះគេចមកនៅនឹងអ្នកសៀវៗ ក៏ឲ្យតាន់លឹមធ្វើសំបុត្រតាមពាក្យគួតៅថា ៗ

(មានត)

# ណាលះ និង ទមយន្តី

## រឿងព្រេងប្រទេសឥណ្ឌា

### អ្នកស្រីស្រ៊ិន-សារ៉ិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

*ប្រែពីភាសាបារាំងមកជាភាសាខ្មែរ*

(តមក)

---

ពួកឈ្មួញនាំគ្នាធ្វើដំណើរតទៅទៀត ទាំងព្រួយបារម្ភ, ព្រះនាងទមយន្តីទ្រង់យាងតាមក្រោយគេ ដោយមានព្រះទ័យស្រពោនអណ្តែតអណ្តូង ហើយមានដំណើរបែបល្ហើយ ៗ ក្រោយមកព្រះនាងបានយាងដល់ទៅក្រុងចេទីស៍ ដែលជាប្រទេសនៃព្រះបាទសុវហុ ។

*
* *

ភាគទី ២៥

អ្នកដើរនៅផ្លូវនាំគ្នាមើលព្រះនាង ដែលមានឫកពាជាអ្នកធំ ប៉ុន្តែទៅជាមានសក់ស្រយាក ជើងជាប់ឈាមហូរហាមហើយស្លៀកសំពត់គគ្រើមរហែករយ៉ៃ ដើរមិនចំពោះទៅតាមវិថីណាក្នុងក្រុង ។ ពួកកូនក្មេងនាំគ្នាដើរតាមព្រះនាងដោយចង់ដឹង ខ្លះទៀតនាំគ្នារិះគន់ព្រះនាងចួនកាលថែមទាំងយកដុំថ្មបោះបេព្រះនាង ។

ព្រះនាងយាងដល់មុខព្រះបរមរាជវាំង ។ ឯអគ្គមហេសីស្តេច, ព្រះរាជបុត្រី និងស្រីស្នំក្រមការ គាល់ស្តេចត្រៀបត្រានៅលើព្រះ

កដដំណាក់, លុះស្តេចឃើញព្រះនាងទមយន្តីយាងមកដល់ ទ្រង់មានព្រះហឫទ័យអាណិតណាស់ ក៏ប្រើស្នំម្នាក់ថា: "ចូរឯងនាំស្រីកំសត់នោះមកទីនេះ នាងនោះបែបលំបាកខ្លាំងណាស់ ប៉ុន្តែមើលទៅបុគពា ព្រមទាំងដំណើរដូចមិនសមជាអ្នកខ្សត់ខ្សោយ, ពួកក្មេងនាំគ្នាមើលដោយគ្នាពេក យើងត្រូវតែជួយសង្រ្គោះគ្នា" ។

យូរបន្តិចមក ស្នំនាំព្រះនាងទមយន្តីមកថ្វាយបង្គំព្រះវររាជជននីដែលទ្រង់ឆ្ងល់ដោយបានពិនិត្យឃើញព្រះនាងមានរូបថ្លៃក ហើយទ្រង់មានបន្ទូលសួរថា: "តាមដែលខ្ញុំឃើញអ្នកវេទនាខ្លាំងណាស់ អ្នកដើរហាលថ្ងៃ ហាលភ្លៀង ប៉ុន្តែរូបអ្នកនៅតែល្អទៀត សំពែរបស់អ្នកចាំងចេញពីកន្លងសំពត់រហែក ហាក់ដូចជាពន្លឺធ្លុះចេញពីដុំពពក អ្នកអាចធ្វើឲ្យពិភពលោកឃើញបាន ដោយមិនបាច់មានគ្រឿងតែងខ្លួនផង មិនតែប៉ុណ្ណោះ អ្នកមានចិត្តក្លាហានថែមទៀត ពួកក្មេងនាំគ្នាដេរអ្នកៗ នៅតែធ្វើព្រងើយកន្តើយទៀត ចូរអ្នកប្រាប់យើងមើល តើអ្នកជាអ្វី?" ។

ព្រះនាងទមយន្តី ថ្វាយបង្គំព្រះវររាជជននី ហើយទូលតបថា: "ទូលព្រះសវនីយ៍សូមទ្រង់ជ្រាប! ខ្ញុំម្ចាស់ជាកូនអ្នកមានពូជល្អដែរ ប៉ុន្តែកម្មអកុសលតាមមកផ្តល់ខ្ញុំម្ចាស់ បានជាខ្ញុំម្ចាស់ធ្លាក់ក្រលំបាកគោកយ៉ាកទទួលទានតែមើមឈើនិងផ្លែឈើជាអាហារ ជាយូរថ្ងៃកមហើយ, ខ្ញុំម្ចាស់គ្មានគីគ្នាទេ ពេលយប់មកដល់កន្លែងណា ខ្ញុំម្ចាស់ឈប់ទទួលទាន

ដំណេកនៅកន្លែងនោះ, ក៏ប៉ុន្តែប្ដីខ្ញុំម្ចាស់ប្រកបដោយគុណធម៌ល្អណាស់ មានចិត្តស្មោះស្ម័គ្រនឹងខ្ញុំម្ចាស់ណាស់ បានជាខ្ញុំម្ចាស់ចេះតែដើរតាមរកហាក់ដូចជាស្រមោល អន្ទោលតាមរូប, រាសនាអាក្រក់ធ្វើឲ្យប្ដីខ្ញុំម្ចាស់លេងល្បែងពាល់តែចាញ់អស់ទ្រព្យសម្បត្តិគ្មានសេសសល់, មុនដំបូងយើងទាំងពីរនាក់នាំគ្នាដើរកាត់រាលកាត់ព្រៃ ស្រាប់តែថ្ងៃមួយខ្ញុំម្ចាស់ក្រោកឡើងរកប្ដីខ្ញុំម្ចាស់មិនឃើញមិនដឹងជាទៅឯណា បានជាខ្ញុំម្ចាស់កើតទុក្ខដល់ម៉្លេះ" ។

ព្រះវរកដជននី ទ្រង់ទតព្រះនាងដោយមានព្រះទ័យរំជួលអាណិត ហើយមានព្រះបន្ទូលថា: "ណ្ហើយចុះ នាងឯងកុំដើរទៅណាទៀត នៅជាមួយនឹងយើងទៅ ក្រែងលោប្ដីនាងដើរកាត់តាមក្រុងនេះ បើនាងចូលចិត្តនៅ យើងនឹងប្រើព្រាហ្មណ៍ឲ្យទៅរកប្ដីនាង១ នៅក្នុងប្រាសាទយើងជាទីសុខចុះ, មនុស្សនៅក្នុងដំណាក់យើងទាំងអស់សុទ្ធតែមានចិត្តរាប់អាននាង" ។ ព្រះនាងទមយន្ដីនៅស្ងៀមដោយរំជួលចិត្ត ដោយឃើញម្ចាស់ក្សត្រីមានព្រះហឫទ័យសប្បុរសពន់ពេក ព្រះនាងរៀបតែនឹងបើកព្រះឱស្ឋក្រាបទូលព្រះវរកដជននី តាមរឿងរ៉ាវត្រង់ពិតទៅហើយ ប៉ុន្តែសេចក្ដីអៀនខ្មាសមកឃាត់ព្រះនាងភ្លាម ព្រះនាងទ្រង់ព្រះតម្រិះមួយសន្ទុះ ហើយទូលព្រះមហាក្សត្រីថា: "ព្រះវរកដជននី! ការដែលទ្រង់ប្រោសប្រណីខ្ញុំម្ចាស់យ៉ាងនេះ ធ្វើឲ្យខ្ញុំម្ចាស់រសាយទុក្ខ ខ្ញុំ

ម្ចាស់សុខចិត្តនៅគាល់បំរើព្រះមហាក្សត្រ បើសិនជាទ្រង់មេត្តាព្រម ព្រៀងនឹងពាក្យដែលខ្ញុំម្ចាស់សូមព្រះរាជទានពរ" ។

ព្រះវររាជជននីទ្រង់តបដោយញញឹមថា: "យើងមានសេចក្ដីឆ្ងល់ណាស់ បើសិនជាពាក្យសុំរបស់នាងគ្មានទំនង" ។. ព្រះនាងទូលថា: "ទី ១ ខ្ញុំម្ចាស់សូមទ្រង់កុំទុកខ្ញុំម្ចាស់ជាទាសី, ទី ២ បុរសណាក៏ដោយដែលមានការចង់និយាយនឹងខ្ញុំម្ចាស់ ទាល់តែខ្ញុំម្ចាស់ព្រមទើបនិយាយបាន ។· បុរសណាចង់បានខ្ញុំម្ចាស់ជាប្រពន្ធក្ដី ជាស្រីកំណាន់ក្ដី ខ្ញុំម្ចាស់សូមព្រះរាជានុញ្ញាតធ្វើទណ្ឌកម្មដោយដៃខ្ញុំម្ចាស់ ហើយបើសិនជាផ្តាលក់យ៉ាងនេះហើយ កនៅតែមករំខានខ្ញុំម្ចាស់ទៀត ខ្ញុំម្ចាស់សូមអំណាចសម្លាប់ចោល ខ្ញុំម្ចាស់នឹងប្រស្រ័យការជាមួយតែនឹងព្រាហ្មណ៍បណ្ឌិត ហើយខ្ញុំម្ចាស់នឹងគិតរកឧបាយកលនឹងរកប្ដីខ្ញុំម្ចាស់ឲ្យឃើញ, ចំពោះតែព្រាហ្មណ៍ទេ ដែលខ្ញុំម្ចាស់ប្រាប់ឈ្មោះនឹងប្រាប់ស្រុកកំណើតពិតនេះហើយដែលជាសេចក្ដីសុំរបស់ខ្ញុំម្ចាស់" ។,

– "នាងឯងមានគតិបណ្ឌិតមែន យើងព្រមទទួលពាក្យសុំរបស់នាង" ហើយទ្រង់ក៏មានបន្ទូលហៅព្រះរាជបុត្រី:

– "សុនន្ទា! (Sunanda) នាងនេះមានអាយុស្មើនឹងនាងដែរ ចូរនាងរាប់រកគ្នាដូចជាមិត្រសំឡាញ់ទៅ ហើយចូរនៅឲ្យសុខជាមួយគ្នា" ។

ព្រះនាងទមយន្ដីនឹងព្រះនាងសុនន្ទា ក៏ទទួលគ្នាដោយមេត្រីភាព ។

## ភាគទី ២៦

ព្រះបាទនាលៈ ក្រោយពីបានចេញចោលព្រះនាងទមយន្តីមក ស្តេចយាងកាត់ព្រៃ ទ្រង់យាងទៅប្រទះព្រៃស៊ុំទ្រុមមួយដែលកំពុងតែឆេះភ្លើងយ៉ាងខ្លាំង ព្រះអង្គទ្រង់ឮសូរសំឡេងមួយស្រែកចេញពីក្នុងអណ្តាតភ្លើងមកថា: "ឱនាលៈ អ្នកប្រកបដោយគុណធម៌អើយ! មកជួយខ្ញុំផង!" លុះឮដូច្នោះហើយ ព្រះអង្គក៏ទ្រង់យាងចូលទៅក្នុងគុម្ពោតដោយគ្មានញញើតនឹងភ្លើងសោះ ទ្រង់ទតយល់នូវនាគរាជមួយ ញ័ររន្ធត់នៅកណ្តាលភ្លើង ទ្រង់មានព្រះបន្ទូលថា "កុំភ័យ" ហើយទ្រង់ចាប់ទាញនាគនោះចេញពីក្នុងភ្លើងមក ៗ នាគនោះកំរើកខ្លួនដោយសេចក្តីត្រេកអរណាស់ ហើយក៏បែរមករកស្តេច ទូលថា: "សូមអរព្រះគុណព្រះករុណាជាម្ចាស់ដែលក្លាហានយកព្រះអង្គជួយសង្គ្រោះជីវិតទូលព្រះបង្គំ, ទូលព្រះបង្គំបានទៅរំខានឥសីមួយអង្គដែលកំពុងតែចំរើនឈាន ឥសីនោះក្តៅណាស់ ក៏ដាក់បណ្តាសាឲ្យទូលបង្គំនៅទីនេះតែមួយកន្លែង លុះត្រាតែព្រះបាទនាលៈបានមកពាល់ដល់ខ្លួនទូលព្រះបង្គំ ទើបទូលព្រះបង្គំរួចចេញពីទីនេះទៅបាន, ភ្លើងរៀបតែនឹងឆាបដល់ខ្លួនទូលព្រះបង្គំទៅហើយ ទទួលព្រះអង្គយាងមកដល់ ហើយឮពាក្យទូលព្រះបង្គំហៅឲ្យជួយ, ទ្រង់បានជួយជីវិតទូលព្រះបង្គំ ៗ សូមអរព្រះគុណ" ៗ

— "ការជួយសង្គ្រោះអ្នកមានទុក្ខនេះ ជាករណីយកិច្ចរបស់ខ្ញុំ" ៗ

- "ដើម្បីនឹងបង្ហាញសេចក្ដីកតញ្ញូរបស់ទូលបង្គំ ។ នឹងទូលអំពីអនាគតរបស់ព្រះអង្គ" រូបទូលថា:

- ទ្រង់ត្រូវនៅសោយទុក្ខទៀត ដូច្នេះទ្រង់ត្រូវលាន់ប្បាបឲ្យជ្រះ" ។

- "យី ខ្ញុំបានប្រមាថអាទិទេព ដោយធ្វើកម្មអកុសលអ្វី?" ។

- "ចុះព្រះអង្គទ្រង់ចាំទេ នៅវេលាយប់មួយដែលទ្រង់ស្រវាលស្ល្បែងបរបាញ់សត្វជាមួយនឹងរាជបុត្រ, នៅពេលនោះ ទ្រង់ស្ងួនកន្ល្បែងពេក ទាល់តែក្មេចស្បូត្រនមស្ការព្រះអាទិទេពតាមទំនៀម" ។

- "មែនហើយ... មែនហើយ... ខ្ញុំនឹកឃើញហើយ ឥឡូវនេះ ទើបខ្ញុំដឹងនូវជោគវាសនាអាក្រក់របស់ខ្ញុំ!" រូបព្រះអង្គទ្រង់ថ្ងូរទះតបទ្រូក ។

នាគក៏ទូលតទៅទៀតថា "ព្រះករុណាស្ដេចកុំអស់សង្ឃឹម, ព្រះអង្គគង់តែបានជួបនឹងព្រះនាងទមយន្ដីនឹងព្រះរាជបុត្រទាំងពីរពុំខាន គេនឹងប្រគល់ព្រះរាជអាណាចក្រថ្វាយទ្រង់វិញ ប៉ុន្ដែបាបកម្មរបស់ទ្រង់ពុំទាន់អស់ទេ ដូច្នេះ សូមទ្រង់យាង ២០ ជំហានទៅចំអូរដែលទ្រង់ទតឃើញនៅខាងមុខនោះទៅ" ។

ព្រះបាទនាលៈក៏ធ្វើតាមបង្គាប់ ។

- "បានហើយ ឥឡូវនេះសូមទ្រង់ដកដៃត្រង់នេះទៅ" ។

ព្រះបាទនាលៈក៏ធ្វើតាមបង្គាប់ទៀត ។ ទ្រង់កកាយដីបន្តិចទៅទ្រង់ឃើញអាវក្រហមមួយធ្វើអំពីសំពត់គក្រែម ។ (មានត)

## ដំណឹងតាមខ្យល់ក្នុងកន្តារៈ

### លោកផេង-ជ្រឹវ សាស្ត្រាចារ្យនៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

(តមក)

---

ពួកជនជាតិអារ៉ាប់ក្នុងប្រទេសអាហ្វ្រិក កាលណាបើគេមានការត្រូវជជែកសូម្បីកិច្ចអ្វីតូចមួយ ជាមួយនឹងពួកសេយ្យសាសន៍ តែងតែសុំតវ៉ាឥតញញើតយកការទំនុកបំរុងមហាម័តមកវិញ ទោះបីពួកសាសនិករបស់លោកនេះមិនជាទីគាប់ចិត្តដល់គណៈរបស់គេក៏ដោយ ។

ក្នុងសម័យដែលកើតមានរឿងនេះឡើង សាសន៍អ៊ីតាលីបាននាំកងយោធាទៅឡើងនាច្រាំងស្រុកចំណុះរបស់សាសន៍ទួរគី ដោយមានបំណងនឹងវាយស្រុកវិទ្យារយិត ជាដាច់ស្រេច ។

កិច្ចទីមួយនៃរដ្ឋាភិបាលទួរគី គឺត្រូវប្រមូលជនជាតិអ្នកស្រុកអាយទាំងអស់មកចងបាច់ជាមួយគ្នា ដោយពោលឃោសនាថានឹងធ្វើចម្បាំងសាសនាទប់នឹងពួកខ្មិល ។ ដ្បិតការប្រកាន់ចំពោះសាសនា មានសិទ្ធិដ៏ក្លៀវក្លាតាំងនៅជាស្ថាពរក្នុងសន្តាន នៃពួកប្រជាជនប្រកាន់កោតុលហមង្គល ។

ការប្រកាន់សាសនា តែងបញ្ជាក់ឲ្យឃើញដល់ភ្នែកជនដទៃ សូម្បីតែក្នុងពិធីបុណ្យរប៉ិចរប៉ុកក៏ដោយ មិនចាំបាច់ដល់ទៅការធ្វើបុណ្យជាអធិកៈ

ធំក ប្រកបដោយក្បួនដ៏ថ្លៃថ្លា ដូចជាពិធីខួបរបស់លោកម៉ាហូមេត ឡើយ ។ ហេតុដូច្នេះ ពួកបរិស័ទនាំគ្នាដើរហែពពាក់ពពូន បែនបត់ តាមថ្នល់ដ៏ចង្អៀត ពីខាងក្រោយ ពួកលោកសង្ឃដែលពាំដែកគោល ដុតយ៉ាងក្រហម ពាំអំបែងកែវ នឹងខ្សាជ័រទាំងរស់ ម្យ៉ាងទៀត ត្រូវ ពិនិត្យមើល តើយ៉ាងដូចម្តេចកម្លាំងចិត្តដ៏ខ្ជាប់ខ្ជួនហើយកោះជាប់នៅក្នុង ដួងហ្ឫទ័យនៃពួកម៉ាហូមេតង់ ក្នុងកំហឹងស៊ីសាច់របស់គេ ចំពោះស្នាម ឬមាគ៌ានៃអារ្យធម៌ជាតិពេម៉ាំង ។

លុះការផ្សាយថាមានចម្បាំងសាសនាហើយ នាយកងទ័ពទួរគី អាចទីពឹងលើជំនួយជាទុក៏លាំនៃប្រជាជនអាក៏ប់បាន ។ ចំណែកខាងពួក ប្រជាជាតិអាក៏ប់ខ្លះដែលកាន់សាសនាផ្សេង ក៏រដ្ឋាភិបាលនៃម៉ាហូមេត មិនមានសេចក្តីញ៉ាក់ញញើតឡើយ ។

ប្រជាពស្ត្រីក្នុងស្រុកធ្លាប់ចេះបាញ់កាំភ្លើងដោយត្រឹមត្រូវស្រាប់ ។ ពល់តែវេលាពិធីបុណ្យ គេតែងហៅពួកកងកាំភ្លើងនេះមកជាជំនួយ ឃើញការបាញ់កាំភ្លើងស្រុះគ្នា, នេះបណ្តាលឲ្យដឹងថាគេប្រើការបាន កាលណាមានអាសន្នកើតឡើង ។

ចំណែកខាងពួកអ្នកចរាចរកំវិញ គេសម្រេចថាត្រូវឲ្យប្រមូល មនុស្ស ប្រមូលគ្រឿងសញ្ញាវុធនឹងសត្វពាហនៈ ហើយយកមកឃុំទុកក្នុ ឲ្យទៅណា នៅក្រោមការដំរៀន នឹងសេចក្តីខុសត្រូវរបស់លោកតាអ៊ុត ។ នេះជាយោបល់របស់លោកម៉ាហូមេតណាប៊ី-បៃ ជាវរសេនីយ៍ត្រីតួត

ទៅប្រចាំក្រុងកាសិ-កាពបូលី ។ លោកមានបង្គាប់ឲ្យដឹកនាំរហូតដល់ជាយក្រុងតូចមួយ នូវពួកចុកចរក្រៅព្រមទាំងអាវុធយុទ្ធភ័ណ្ឌ និងប្រដាប់ប្រដាសព្វសារពើ ដែលពួកនេះនាំគ្នាតាំងជំរំនៅ មានចម្ងាយពីរបីគីឡូម៉ែត្រពីមាត់ព្រលខ្សាច់ ។

លោកអនុសេនីយ៍ទោម្នាក់ជាមួយនឹងកងទាហានសេះ បានទៅកាន់ផ្លូវឈ្មោះ ស៊ូអាក់ ដែលឃើញមានជំរំបោះនៅទីនោះ, ហើយគឺជារឿងដ៏ឈឺចាប់ដែលនាំងនាំឡើងទៀត ឈរលើខ្នងបរតេតពីខាងលើទីព្រលប្រកក្លា ក្រឡេកមកបានប្រទះឃើញ ។

ហេតុដូច្នេះ កាលណាលោកតាម៉ាព្រែកអែលគាឌី បានមកតាំងនៅចំពោះមុខហើយ នាយទាហានក៏ថ្លែងប្រាប់សេចក្ដីដូចតទៅនេះ ៖

– "ចម្បាំងសាសនាកើតឡើងវាល់ឥស្លាម នឹងពួកទិល, ខ្ញុំបានទទួលបទបញ្ជាត្រូវឲ្យមកកេណ្ឌមនុស្ស សត្វពាហនៈព្រមទាំងនាំលោកតាយកទៅរហូតដល់ក្រុងកាសិ-កាពបូលី" ។

លោកតាម៉ាព្រែកយល់ថា រឿងនេះប្រហែលជាមូលហេតុនៃសេចក្ដីវិនាសដ៏ពិតប្រាកដដល់កុលសម្ពន្ធរបស់គាត់ ។ គាត់ខំនិយាយតវ៉ារតាវនិយាយជំទាស់ហើយនឹងខំល្បងអធិប្បាយអំពីរឿងផ្សេងៗ ដើម្បីធ្វើឲ្យប្រេសិតតួគ័ស្ដាប់បាន ។ គឺខណៈនោះហើយដែលនាយទាហានបញ្ចេញក្រដាសមួយច្បាប់ធ្វើទាំងពីរភាសាៈ ទួរគីនិងអារ៉ាប់ , នៃព្រះចៅស៊ុលតង់ហុចឲ្យគាត់មើល ។ ក្នុងក្រដាសនោះមានសញ្ញាព្រះនាមព្រះ

ទៅទួរគី ទីងឈ្មោះលោកកាអ៊ីត ហើយមានដាក់សេចក្ដីខាងចុងថា: បើផឹងទឹងត្រូវប្រើកាំជ្រា ។

ក្នុងឱកាសនោះ លោកតាម៉ាព្រែកត្រូវតែស៊ូអត់ទាំព្រមទទួលជោគវាសនាអាក្រក់ដែលធ្លាក់មកលើ ។ គាត់មានវាចាថា: សូមសេចក្ដីស្ម័គ្រនៃព្រះអាឡស់សម្រេចចុះ ។ រួចគាត់បែរមុខចំពោះទៅពួកមិត្តស្ម័គ្ររបស់គាត់ ដែលមានកំហឹងកាន់ត្រៀមចាំជាស្រេច ហើយបង្គាប់ទាំងមុខស្រងូតថា: ចូរដាក់អាវុធចុះ ការប្រយុទ្ធមិនស្មើកម្លាំងគ្នា ប្រតិបត្តិការមានប្រយោជន៍អ្វីបើឃើញថាញាំដៃគេមុនរួចទៅហើយ បើយ៉ាងដូច្នេះមិនត្រូវយកឈាមរបស់មនុស្សដែលនៅក្នុងអាណាព្យាបាល ហើយមានសេចក្ដីទុកចិត្តលើខ្លួនដូចជាឪពុក ទៅក្រាលលើផែនដីដូនជីតាឡើយ ។

ពួកបកបរក៏នាំគ្នាបត់សំពត់ជុំវិញទាំងស្រងូតស្រងាត់ ។ គេនាំគ្នាគោរពនូវចិត្តស្ម័គ្ររបស់នាយហៅហ្វាយ ។

កាលណាតែកិច្ចការសព្វគ្រប់គេប្រុងប្រៀបស្រេចហើយ ៗ មើលទៅទឹកន្ទែងនៅតែជីវលើងណឹល គេតាំងឈរតម្រៀបគ្នាជាបែបក្បួនដំណើរយ៉ាងល្អដោយស្ងៀមស្ងាត់ មានលោកតាម៉ាព្រែកនៅជាខាងក្រោយ បន្ទាប់មកគឺពួកទាហានសេះ គេធ្វើដំណើរសំដៅទីក្រុង ។

នាងក្រមុំ ឡូឡា តាមក្រឡេកមើលពួកអ្នកដំណើររហូតផុតកន្ទុយភ្នែកដោយពន្លឺរស្មីនៃព្រះសូរ្យសាយណ្ហ ។ (មានត)

# រឿងបល្ល័ង្កទិព្យ សាមសិបពីររឿង

### រឿងព្រេងឥណ្ឌា

## លោកសមិន ម្ចត្យនជិមះ តែង

## លោកប៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

---

### អារម្ភកថា

រឿងបល្ល័ង្កទិព្យ សាមសិបពីររឿងនេះ គឺពណ៌នាអំពីព្រះមហាក្សត្រិយ៍វិក្រមាទិត្យ ។ ព្រះមហាក្សត្រិយ៍អង្គនេះ មានព្រះកិត្តិនាមល្បីល្បាញក្នុងប្រវត្តិសាស្ត្រឥណ្ឌា; ក្នុងរជ្ជកាលព្រះអង្គ ជាសម័យដែលវប្បធម៌ឥណ្ឌាឡើងកាន់វឌ្ឍនធម៌ពេញបរិបូណ៌ ដោយមានបណ្ឌិតជាច្រើនបានចូលទៅសន្និបាតក្នុងព្រះបរមរាជវាំង ។

សម័យព្រះបាទវិក្រមាទិត្យនៃប្រទេសឥណ្ឌា បើប្រៀបធៀបនឹងប្រទេសក្រិក គឺ សម័យប៉េរិគ្លេស, ប្រទេសរ៉ូម៉ាំង សម័យអូគុស្ត, ប្រទេសអ៊ីតាលី សម័យមហារាជឡេអុងទីដប់, ប្រទេសបារាំង គឺសម័យមហារាជល្វីទីដប់បួន ។

ប៉ុន្តែពិតមែនតែព្រះបាទវិក្រមាទិត្យ ជាមហារាជមានព្រះរាជកិត្តិនាមល្បីល្បាញ, តែប្រវត្តិសាស្ត្រសាកលមិនបានទទួលស្គាល់ព្រះអង្គសោះឡើយ ព្រោះន័យខាងប្រវត្តិសាស្ត្រពួកជនជាតិឥណ្ឌាមិនសូវពេញចិត្តនឹងផ្សាយ ឬមិនសូវស្គាល់នូវអត្ថរស បានជាទៅរចនារឿងព្រេង

មួយឲ្យឈ្មោះថា "បល្ល័ង្កទិព្យ សាមសិបពីររឿង" ដើម្បីនឹងផ្សាយខ្ចរកិត្តិយសនៃព្រះបាទវិក្រមទិត្យ ។ ឯព្រះរាជចរិយាដ៏វិសេសនៃព្រះអង្គ. បណ្ឌិតឥណ្ឌាបានយកទៅផ្សាយក្នុងរឿងនេះ ព្រមទាំងរឿងវេតាលៈ ឬ "ការក្សៃថ្ងៃរឿងម្ភៃប្រាំ" ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដី "កម្ពុជសុរិយា" ឆ្នាំ ១៩៥២; បើលោកអ្នកចង់ជ្រាបរឿងនេះ សូមអញ្ជើញទៅជាវឯពុទ្ធសាសនបណ្ឌិត្យមកអានចុះ ។

តែរឿងបល្ល័ង្កទិព្យសាមសិបពីររឿងនេះ (បើតាមភាសាសំស្ក្រឹត សិង្ហាសន., ទ្វាត្រឹម្សតិ, Sinhàsana-dvatrimçati) ជារឿងពណ៌នាចំពោះព្រះបាទវិក្រមទិត្យតែមួយព្រះអង្គ ។ អ្នកនិពន្ធបាននិពន្ធដើមដំបូងជាភាសាសំស្ក្រឹត, តមកបានបណ្ឌិត សុន្ទរ (Sundar) ប្រែមកជាគ្រាមភាសា (diale cte) ព្រជ-ភាខា (Bbraj-bhàkhà) ដោយមានព្រះរាជ-បញ្ជាពីព្រះមហាក្សត្រិយ៍ សាហ៍-ជិហាន (Shah-Jehân) រួចលោកលល្លុ (Lallu) បានប្រែមកជាភាសា ហិណ្ឌុស្ថានី-អ៊ុរទុ ។ តែសៀវភៅនេះគឺលោកឡេអុងហ្វែរ (Léon Fer) បានបកចេញពីសៀវភៅលោកសមិនមុត្យុនជម: (Çarmen Mrityanjama) មាននាមថា: "ពត្រិស-ប៉ុតាលិកា សិង្ហាសន, (Batris putalika Sinhâsan) ដែលបោះពុម្ពនៅក្រុងឡុង គ.ស. ១៨១៥ ។

ខ្ញុំបាទអានរឿងនេះឃើញថា មានសារៈប្រយោជន៍ បានជាខ្ញុំព្យាយាមបកប្រែមកជាភាសាខ្មែរសម្រាប់ឲ្យជនជាតិយើងអាន, ពិចារណា

ដើម្បីឲ្យកើតសតិប្រាជ្ញាឡើង ។ ឯវត្ថុបំណងរបស់ខ្ញុំនេះ គឺ មាន ប្រាថ្នាដើម្បីនឹងឲ្យជនជាតិខ្មែរ ដែលជាបងប្អូនរួមឈាមជាមួយមាន បំណោះវិជ្ជាគ្រប់ៗគ្នាឡើង ព្រោះថា៖

"មុននឹងកសាងជាតិ ឬ មាតុភូមិ ត្រូវកសាងមនុស្សសិន, កាលកសាងមនុស្សបានហើយ, ជាតិឬមាតុភូមិក៏ងាយនឹងកសាងឲ្យទៅកាន់វឌ្ឍនធម៌" ។

ព្រោះហេតុដូចនេះ, ខ្ញុំសូមឧទ្ទិសផលកុសលដែលកើតឡើង ដោយសេចក្ដីព្យាយាមនេះ ជូនទៅមាតុភូមិគឺប្រទេសកម្ពុជា, សូមឲ្យបានឆ្ពង់ផុតផ្លូវគន្ដារទៅដល់ស្ថានបរមសុខ, ព្រមទាំង ឧបាសិកា ផ្លូ ជាមាតារបស់ខ្ញុំ សូមឲ្យបានប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ តទៅហោង ។

កំពេញនៅថ្ងៃទី ៣ កញ្ញា ឆ្នាំ ១៩៤៤

ប៉ាយ-ប៊ុគ

# សេចក្តីសង្ខេបក្នុងរឿងបល្ល័ង្កទិព្យ

មហារាជវិក្រមទិត្យ ជាព្រះមហាក្សត្រិយ៍មួយអង្គមានព្រះរាជានុភាពលើសស្តេចទាំងអស់ ដោយព្រះអង្គមានព្រះប្រាជ្ញាមោះមុតអាចយល់ជាក់ច្បាស់នូវវត្ថុដែលមានអត្ថដ៏សុខុមភាព និងវត្ថុខាងមនុស្សជាតិ ។ ទ្រង់បានទទួលព្រះរាជអំណោយពីសក្កទេវរាជនូវបល្ល័ង្កទិព្យមួយ មានរចនារូបទេពនិម្មិតសាមសិបពីរអង្គ ដែលមានតែទ្រង់មួយអាចគង់បាន ។ លុះព្រះមហាក្សត្រិយ៍អង្គនេះសោយព្រះទិវង្គតទៅ បានយាងទៅសោយផលជាទិព្វឯស្ថានសួគ៌ ។ ព្រះបល្ល័ង្កទិព្យនោះមិនមានព្រះមហាក្សត្រិយ៍អង្គណាមានតេជានុភាពអាចគង់លើបាន ។ ព្រះបល្ល័ង្កទិព្យនេះក៏ត្រូវគេយកទៅកប់ក្នុងដី ។ ដល់ថ្ងៃក្រោយមក, មានព្រះមហាក្សត្រិយ៍ទ្រង់ព្រះនាម ភោជៈ បានសោយរាជសម្បត្តិ ទ្រង់បានរកឃើញនូវព្រះបល្ល័ង្កទិព្យនោះ ។ បានជាមានពណ៌នារឿងរ៉ាវដូចតទៅនេះ ។

(មានត)

# ពិធីបុណ្យឆ្លងសាលាបាលីរង

## វត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប

## លោកគ្រូបាសាទវង្សីអនុគណ កែ-អឿន (វីរិយប្បញ្ញោ)

រៀបរៀង

---

កាលពីថ្ងៃ ៩-១០-១១ កើតខែជេស្ឋ ឆ្នាំមមីឯស័ក ព.ស. ២៤៩៧ គឺថ្ងៃទី ៩-១០-១១ ខែមិថុនា គ.ស. ១៩៥៤ នៅវត្តព្រះព្រហ្មរតន៍ ខេត្តសៀមរាប មានធ្វើពិធីបុណ្យដ៏រុងរឿងគឺ បុណ្យឆ្លងសាលាបាលីរង និង បុណ្យបញ្ចុះអដ្ឋិធាតុឱង-ប៉ុគី ។ ពិធីបុណ្យនេះមានការតាក់តែងវិចិត្របនាដ៏ឧឡារិកអធិកមហិមា; ក្នុងទីវត្តទាំងមូលគេសំអាតគ្រប់កន្លែងដូចមានវិធានការចាត់ចែងតទៅនេះ ៖

## ខាងក្នុងសាលាបាលី

សាលាបាលីនេះមានរៀបចំជារបៀបដ៏ស្អាត, ត្រង់បន្ទប់កណ្ដាលមានថូបស្ថានមួយធ្វើពីថ្មម្ហបសម្រាប់បញ្ចុះអដ្ឋិធាតុ បណ្ដោយជាង ១ ម៉ែត្រ ទទឹង ១ ម៉ែត្រ កំពស់ជាង ១ ម៉ែត្រ ។ នៅជញ្ជាំងសាលាខាងជើងថូបស្ថាននោះ ដម្កល់ព្រះពុទ្ធរូបកញ្ចក់ធំ ១ ព្រះអង្គ ខាងមុខរៀបតុជាថ្នាក់ៗ ដាក់គ្រឿងសក្ការបូជា; ខាងលើថូបស្ថាននោះក៏រៀបគ្រឿងសក្ការបូជាដែរ, នៅជញ្ជាំងជុំវិញដាក់អំពូលភ្លើងតូចៗ មានពណ៌គ្រប់បែប ៗ

# យ៉សាលាបាលី

នៅយ៉សាលានេះ ត្រង់កណ្ដាលមានបុស្បុក ១ កំពស់ ៣ ម៉ែត្រ ទំហំជុំវិញជាង ១ ម៉ែត្រ ៤ ជ្រុង ។ ក្នុងបុស្បុកនោះគេដម្កល់ត្រែធម្មា-សនៈសម្រាប់ធម្មកថិកសំដែងធម៌, សសរបុស្បុកទាំង ៤ មានអំពូលភ្លើងតូចៗ, ខាងក្រៅជុំវិញសសរ ព័ន្ធព័ទ្ធសំពត់ប៉ាក់គ្រឹប, ខាងមុខបុស្បុករៀបតុដាំខ្សែជាថ្នាក់ៗ ដាក់គ្រឿងសក្ការបូជា, នៅកណ្ដាលយ៉ មានចងសំពត់ប៉ាក់គ្រឹបសំយុងចុះមកទាំង ៤ ជ្រុង មានសណ្ឋានដូចជាមេឃ; ខាងលើបណ្ដោយទៅ ចងទង់ជាតិទង់សាសនាខ្សែវែងប្រទាក់ខ្វាត់ខ្វែង; នៅជម្រូលសាលាខាងមុខ ដាក់អំពូលភ្លើងធំ - តូច គ្រប់ពណ៌ចម្រុះគ្នាជាង ១ ០០០ អំពូល ។

# ខាងមុខសាលាបាលី

ខាងមុខសាលាមានធ្វើពេងពារ ប្រក់សំពត់របៃសំយុងចុះមកជុំវិញដោយសំពត់ជាតិ ទឹងក្រមងស្លឹកដែក្រម, នៅសសរនីមួយៗ សុទ្ធតែស្រោបដោយស្លឹកទន្សែ មានអំពូលភ្លើងធំៗ, ខាងក្នុងពេងរៀបតុកៅអីជាច្រើន, នៅជម្រូលពេងទាំងពីរនោះ ចងទង់ជាតិទង់សាសនាមានជងខ្ពស់ធំៗ ។ ពេងទាំងពីរនេះសម្រាប់ទទួលភ្ញៀវដែលអញ្ជើញទៅអនុមោទនាបុណ្យ ។ ខាងមុខបន្ទាប់អំពីពេងទាំងពីរនោះមក មានធ្វើពេងធំមួយទៀតប្រក់ស្លឹក សំយាបជុំវិញមានរបៃសំពត់ សណ្ឋានជាទង់

ជាតិ, ខាងកងពេងនេះមានបងទង់ជាតិ-សាសនាវែងៗ នឹងអំពូលភ្លើងធំៗជាច្រើន, ពេងនេះសម្រាប់ទទួលពុទ្ធបរិស័ទជាគ្រហស្ថ ។

## នៅសាលាធម្មសភា

សាលាធម្មសភា ក៏មានការរៀបចំដោយគ្រឿងសក្ការបូជាជាច្រើនណាស់ដែរ, សាលានេះសម្រាប់ប្រគេនភេសជ្ជៈនឹងអង្គាសភត្តាហារដល់ព្រះសង្ឃ ។

## កម្មពិធី

ថ្ងៃទី ១.— គឺថ្ងៃទី ៩ ខែមិថុនា ព.ស. ២៤៩៧ គ.ស. ១៩៥៤ ម៉ោង ១៦ រសៀល ដង្ហែអដ្ឋិធាតុពាក់គេហស្ថាន (ផ្សារសៀមរាប) ទៅដម្កល់ទុកលើថូបស្ថានកងសាលាបាលីថ្មី និមន្តព្រះសង្ឃសត្តប្បករណាភិធម្ម (បង្សុកូល); ម៉ោង ២០ ជួបជុំពុទ្ធបរិស័ទនមស្សការព្រះរតនត្រ័យ និមន្តព្រះសង្ឃចំរើនព្រះពុទ្ធមន្ត រួចនិមន្តព្រះអាចារ្យកែវ-អ៊ុំសំដែងធម៌, លុះទេសនាចប់ហើយ មានបញ្ចាំងរូបភាពយន្ត នឹងលេងល្ខោនខែរ ។

ថ្ងៃទី ២.— គឺថ្ងៃទី ១០ ខែ-ឆ្នាំដដែល ម៉ោង ៨ ព្រឹក បញ្ចុះអដ្ឋិធាតុក្រោមថូបស្ថានកងសាលាបាលីនោះ, និមន្តព្រះសង្ឃសត្តប្បករណាភិធម្ម; ម៉ោង ១១ ថ្វាយចង្ហាន់ដល់ព្រះសង្ឃ; ម៉ោង ២០ ចំរើនព្រះពុទ្ធមន្ត រួចនិមន្តព្រះតេជព្រះគុណព្រះឧបាលិវង្សស្បូរ-ហាយ វត្តឧណ្ណាលោម ក្រុងភ្នំពេញ សំដែងធម៌, លុះទេសនាចប់ហើយ បញ្ចាំងរូបភាពយន្តនឹងលេងល្ខោន ។

ប្រៃទី ៣.— គឺថ្ងៃទី ១១ ខែផ្កាំជជែល ម៉ោង ១០ ព្រឹក ជួបជុំព្រះសង្ឃនឹងគ្រហស្ថនៅសាលាបាលី, ឧង-ប៉ូសាយ សូត្រសុន្ទរកថាដូចមានសេចក្តីតទៅនេះ ៖

ព្រះថេរានុត្ថេរៈ គ្រប់អង្គ! អស់លោក-អ្នកសប្បុរសអ្នកទាំងឡាយ! ខ្ញុំព្រះករុណា, យើងខ្ញុំទាំងឡាយ គឺលោកមាតានាមប្រែម, ឧង-ប៉ូសាយនាងក់គប៉ូ ជាភរិយា, អ៊ុយតាំង-កួយ នាងឧង-ព្រេនជាភរិយា, ឧង-ប៉ូគុណ, តានគិម-វុន នាងឧង-លួមជាភរិយា, ឧង-ប៉ូកា, នាងឧង-អ៊ុយហួយ សូមពណ៌នាអំពីបុព្វហេតុនៃការកសាងសាលាបាលីនេះ ដូចតទៅនេះ ៖

ដើមដំបូងខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នា មានបសាទសទ្ធាជ្រះថ្លាប្រកបដោយកតញ្ញូកតវេទិតាធម៌ចំពោះលោកឧង-ប៉ូគី ជាបិតា ដែលមរណភាពទៅជាយូរឆ្នាំហើយ, យើងខ្ញុំបានគិតគ្នានឹងធ្វើបូជនីយស្ថានដំកល់អដ្ឋិធាតុរបស់លោក តាមប្រពៃណីអំពីបុរាណ ទុកជាទីសក្ការបូជាដល់គុណូបការៈរបស់លោក, តែលោកមាតានាម ប្រែម បានពន្យល់ថា: " ការកសាងវត្ថុនោះ មានប្រយោជន៍ដែរហើយ តែមិនបានជាប្រយោជន៍ធ្ងន់ទៅ, ដូច្នេះត្រូវកសាងសាលាបាលីវិញ ព្រោះសាលាបាលីជាសរសៃនៃព្រះពុទ្ធសាសនា ឬជាបេះដូងជាទីវែងគអាយុព្រះពុទ្ធសាសនា អាចបណ្តុះធម្មវិជ្ជានៃសិក្ខាកាមកុលបុត្រក្នុងព្រះពុទ្ធសាសនា អប់រំព្រះសង្ឃ

ដែលនៅក្នុងមូឡ្ហភាព ឲ្យឡើងទៅកាន់បណ្ឌិតភាព រួចនាំឲ្យមានចំណេះវិជ្ជា ឲ្យមានពន្លឺភ្លឺស្វាង ដើម្បីឲ្យភាសានឹងអក្សរជាតិខ្មែរវិវត្តន៍ទៅកាន់វឌ្ឍនធម៌, ឬអាចនឹងបណ្ដុះវិជ្ជានានាទៀតក៏បេះតែបាន ។ ម្យ៉ាងទៀត អ្នកដែលកសាងសាលាសម្រាប់សិក្សាទុកដូចជាដើមរុក្ខា, ព្រះសង្ឃដែលបានចូលសិក្សាទុកដូចជាបុប្ផាគឺផ្កាដែលមានក្លិនក្រអូប, ឧបាសក-ឧបាសិកា ដែលជួយឧបត្ថម្ភការសិក្សាទុកដូចជាឃ្មុំ ឬកន្ទង់ដែលជញ្ជក់នូវលំអងបុប្ផាទាំងនោះ មកធ្វើជាសំបុក គឺចំណេះវិជ្ជាគ្រប់គ្នា " ។ កាលមាតាយើងខ្ញុំពន្យល់យ៉ាងនេះ យើងខ្ញុំក៏ព្រមតាមយោបល់លោក ។

និមិត្តតែក្តីបំណងនេះកើតឡើងហើយ ក៏បានចាប់ផ្ដើមកសាងសាលាបាលីនេះ ពីឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ គ.ស. ១៩៥៣ ។ សាលាបាលីនេះចែកជា ៣ ភាគ គឺភាគ ២ សម្រាប់ព្រះសង្ឃរៀនសូត្រ, ភាគមួយត្រង់កណ្ដាលសាងជាថូបស្ថាន សម្រាប់បញ្ចុះអដ្ឋិធាតុលោកឧង-ប៉ូគីជាបិតា នឹងជាការិយាល័យ សម្រាប់ចាត់ការព្រះពុទ្ធសាសនា ។ ឥឡូវនេះសាលាបាលីនេះ បានសាងរួចស្រេចដូចបំណងហើយ ។ ពេលនេះយើងខ្ញុំបានធ្វើបុណ្យឆ្លង ព្រមទាំងធ្វើបុណ្យទក្ខិណានុប្បទានបញ្ចុះអដ្ឋិធាតុក្នុងសាលានេះ, ក្នុងពេលបន្ទាប់ពីនេះទៅ យើងខ្ញុំនឹងវេរសាលាបាលីនេះដល់ព្រះសង្ឃទុកជាពុទ្ធសាសនសម្បត្តិតទៅ ។ សូមលោក-អ្នកទាំងឡាយ ជួយអនុមោទនា វេរជាមួយនឹងយើងខ្ញុំ ។

ដោយអានុភាពនៃកុសលកសិដ៏ប្រសើរក្នុងពេលនេះ យើងខ្ញុំជាភរិយានិងបុត្រធីតាទាំងអស់គ្នា សូមឧទ្ទិសផលជូនដល់ដួងវិញ្ញាណនៃលោកឧង-ប៊ុតី ជាស្វាមីនិងជាបិតា សូមឲ្យលោកបែរភក្ត្រាមកទទួលអនុមោទនាយកចំណែកនៃបុញ្ញកម្ម ដែលយើងខ្ញុំបានធ្វើហើយ បញ្ជូនទៅឲ្យក្នុងពេលនេះ ដោយសុវត្ថិភាព! ។

ខ្ញុំបាទ- យើងខ្ញុំ សូមថ្លែងសេចក្តីសោមនស្សដ៏ខ្ពង់ខ្ពស់ ចំពោះអស់លោក - អ្នកសប្បុរសទាំងឡាយ ដែលអញ្ជើញមកឧបត្ថម្ភទំនុកបំរុងក្នុងបុញ្ញពិធីដ៏ឧត្តមនេះ មានឯកឧត្តមអតីតរាជទូតប្រទេសថៃ នាម-ឈុំ និងលោកស្រីដែលបានត្រៀតអញ្ជើញមក ជាអធិបតីនៃបុណ្យនេះជាប្រធាន សូមឲ្យបានចំណែកបុណ្យស្មើៗគ្នា! និងសូមឲ្យសម្រេចឥដ្ឋផលគ្រប់ប្រការ តាមសេចក្តីប្រាថ្នារបស់លោក-អ្នក! មួយទៀតសូមឲ្យបានសម្រេចសម្បត្តិ ៣ ប្រការ គឺ សម្បត្តិក្នុងបច្ចុប្បន្ន ១ សម្បត្តិក្នុងបរលោក ១ សម្បត្តិដ៏ពិសិដ្ឋបំផុតគឺព្រះនិព្វាន ១ កុំបីឃ្លៀងឃ្លាតឡើយ! ។

លុះចប់សុន្ទរកថាហើយ ឧបាសកឡែម-រឿន ជាជំណាងអាចារ្យវត្ត បានផ្តើមវេរសាលាបាលីរង់ដល់ព្រះសង្ឃ ដោយបាលីថា:

- មយំ ភន្តេ ឥមំ ឧបាលិសិក្ខាគារំ សង្ឃស្ស និយ្យាទេម; សាធុ ភន្តេ សង្ឃោ ឥមំ ឧបាលិសិក្ខាគារំ

បដិគ្គណ្ហតុ មាតាបិតាទីនំ គុណវន្តានញ្ចេវ[១] អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ; តតិយម្បិ ។

"បពិត្រព្រះសង្ឃដ៏ចំរើន យើងខ្ញុំទាំងឡាយសូមវេរថ្វាយ នូវសាលាបាលីនេះ ដល់ព្រះសង្ឃ; បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃទទួលយកសាលាបាលីនេះ ដើម្បីសេចក្ដីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់លោក-អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់យើងខ្ញុំទាំងឡាយផង អស់កាលជាអង្វែងទៅហោង ៗ អស់វារៈពីរដងផង; អស់វារៈបីដងផង" ៗ

ចប់វេរហើយ ព្រះសង្ឃទទួល "សាធុ" គ្រប់អង្គ រួចសូត្រអនុមោទនា; ពុទ្ធបរិស័ទសូត្រផ្កាយបត្តិទានគាថា, ទង់-ប៉ូសាយយកទឹកស្មោទកព្រួចដាក់លើពហាស្តព្រះថេរ ៣ រូបគឺព្រះមេគណ-អនុគណ-ចៅអធិការ, បន្ទាប់មក ព្រះគ្រូអនុគណ កែ-អៀន ថ្លែងបាឋកថា ទទួលអំណរសាមីទាន, រួចពុទ្ធបរិស័ទដាក់បាត្រថ្វេនបុណ្យ, ម៉ោង ១៩, ៣០ ទេសនាសង្គាយនា ៗ ចប់ហើយ បញ្ចាំងរូបភាពយន្តនិងលេងល្ខោនជាសម្រេចកិច្ចបុណ្យតែប៉ុណ្ណោះ ៗ

ចប់

១ របៀបបាលី បើប្រើ ច-សព្ទ ពីរឡើងទៅ, ច-សព្ទខាងដើម ត្រូវប្រែកប ឯវ-សព្ទ ។